**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ១៣០ ច.ល

៣រស-០២-០៥-០០១៥០

ផ្ញើទៅព្រះបរមរាជវាំង. រាជធានីភ្នំពេញថ្ងៃទី២៥ ខែឧសភាឆ្នាំ ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

នស/រកត/០៥០២/១៨១

# ព្រះរាជក្រឹត្យ

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និង បន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ០៥ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១- ទណ្ឌិតឈ្មោះ **ហ៊ិន សុផាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧៨ ចុះថ្ងៃទី ២៣-១២-៩៥ លេខ ៣៧៩ ចុះថ្ងៃទី ២៣-១២-៩៥ និងលេខ ៣៨០ ចុះថ្ងៃទី ២៣-១២-៩៥ របស់តុលាការខេត្តបាត់ដំបង។

២- ទណ្ឌិតឈ្មោះ **ឯក សាគុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៥-៩-៩១ របស់តុលាការខេត្តស្វាយរៀង។

៣- ទណ្ឌិតឈ្មោះ **ជា សៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ២៣-៧-៩១ របស់តុលាការខេត្តស្វាយរៀង។

៤_ ទណ្ឌិតឈ្មោះ **អម ខាច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី ២៤-៧-៩៤ របស់តុលាការខេត្តសៀមរាប ។

៥_ ទណ្ឌិតឈ្មោះ **គ្រុន សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ០១-៧-៩៣ របស់តុលាការខេត្តសៀមរាប ។

**មាត្រា ២ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ៣៣ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ :

១_ ទណ្ឌិតឈ្មោះ **ញៀម យី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៥"ក" ចុះថ្ងៃទី ២៥-៧-៩៦ របស់តុលាការខេត្តកំពង់ចាម ។

២_ ទណ្ឌិតឈ្មោះ **ឆាំ ញៀន** ហៅ **ចេន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤"គ" ចុះថ្ងៃទី ១៦-០២-៩៦ របស់តុលាការ ខេត្តកំពង់ចាម ។

៣_ ទណ្ឌិតឈ្មោះ **គន ឡើ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩"ក" ចុះថ្ងៃទី ២៩-០១-៩៦ របស់តុលាការកំពង់ចាម ។

៤_ ទណ្ឌិតឈ្មោះ **ស៊ុន ឡាយហ៊ត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥៩ ចុះថ្ងៃទី ១៥-៨-៩៧ របស់សាលាឧទ្ធរណ៍ ។

៥_ ទណ្ឌិតឈ្មោះ **សោ ព្រឹច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥៤ ចុះថ្ងៃទី ២៥-១០-៩៦ របស់សាលាឧទ្ធរណ៍ ។

៦_ ទណ្ឌិតឈ្មោះ **អ៊ុំ ឃុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦៨ចុះថ្ងៃទី ១៣-១១-៩៦ របស់សាលាឧទ្ធរណ៍ ។

៧_ ទណ្ឌិតឈ្មោះ **អ៊ាច សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលដីកាលេខ ១១ចុះថ្ងៃទី ២១-៤-៩៩ របស់តុលាការកំពូល ។

៨_ ទណ្ឌិតឈ្មោះ **ឃុន សុធី** ហៅ **ភ្លាម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១"ខ" ចុះថ្ងៃទី ០៤-១១-៩៧ របស់តុលាការក្រុងភ្នំពេញ ។

៩_ ទណ្ឌិតឈ្មោះ **ទើ្យ ទុន្ធី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ ២០២ ចុះថ្ងៃទី ០៣-១១-៩៤ របស់តុលាការខេត្តបាត់ដំបង ។

១០_ ទណ្ឌិតឈ្មោះ **ឯក ទណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី ១៨-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

**១១.** ទណ្ឌិតឈ្មោះ **ស៊ិន ហ៊ើម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥៣ ចុះថ្ងៃទី០៦-១២-៩៥ របស់តុលាការខេត្តបាត់ដំបង ។

**១២.** ទណ្ឌិតឈ្មោះ **សួន រ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១៤-០១-៩៤ របស់តុលាការខេត្តបាត់ដំបង ។

**១៣.** ទណ្ឌិតឈ្មោះ **ព្រឿង ព្រេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ២៩-០៤-៩៣ របស់តុលាការខេត្តបាត់ដំបង ។

**១៤.** ទណ្ឌិតឈ្មោះ **ជាន ហ៊ាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ៦ខែ តាមអំណាចសាលក្រមលេខ ៣៧២ ចុះថ្ងៃទី ២១-១២-៩៥ របស់តុលាការខេត្តបាត់ដំបង។

**១៥.** ទណ្ឌិតឈ្មោះ **ខឿន តឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ១៣-០២-៩៥ របស់តុលាការខេត្តបាត់ដំបង។

**១៦.** ទណ្ឌិតឈ្មោះ **ឆោម ឆុន** ហៅ **ជា ភាច** ហៅ **ឈួន ប៊ុនឈឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០១ ចុះថ្ងៃទី ២៧-០៤-៩៥ របស់តុលាការខេត្តបាត់ដំបង។

**១៧.** ទណ្ឌិតឈ្មោះ **ពៅ ទិរៈ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៩ ចុះថ្ងៃទី ១១-៤-៩៥ របស់តុលាការខេត្តបាត់ដំបង។

**១៨.** ទណ្ឌិតឈ្មោះ **ប្រាក់ ហ៊ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ២៥-៦-៩២ របស់តុលាការខេត្តស្វាយរៀង។

**១៩.** ទណ្ឌិតឈ្មោះ **សុក សាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ០៤-៦-៩៤ របស់តុលាការខេត្តស្វាយរៀង។

**២០.** ទណ្ឌិតឈ្មោះ **ឡេង ឡាយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ- តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ២៨-៣-៩៥ របស់តុលាការខេត្តសៀមរាប ។

**២១.** ទណ្ឌិតឈ្មោះ **អ៊ុំ ស៊ីថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០៤-៥-៩៥ របស់តុលាការខេត្តសៀមរាប ។

**២២.** ទណ្ឌិតឈ្មោះ **មូល គេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៨០ ចុះថ្ងៃទី ០៤-៨-៩៥ របស់តុលាការខេត្តសៀមរាប ។

**២៣.** ទណ្ឌិតឈ្មោះ **ថេន នី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ១៧-០១-៩៦ របស់តុលាការខេត្តសៀមរាប ។

២៤. ទណ្ឌិតឈ្មោះ **ហ៊ាំ ច័ក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៣ ចុះថ្ងៃទី ៣០-៥-៩៦ របស់តុលាការខេត្តសៀមរាប ។

២៥. ទណ្ឌិតឈ្មោះ **មាស ស៊ីយ៉ាន** ហៅ **ចន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃទី ០២-៧-៩៦ របស់តុលាការខេត្តសៀមរាប ។

២៦. ទណ្ឌិតឈ្មោះ **ណែន ថារ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ០៨-០១-៩៧ របស់តុលាការខេត្តសៀមរាប ។

២៧. ទណ្ឌិតឈ្មោះ **លុន ឡូញ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ០៨-០១-៩៧ របស់តុលាការខេត្តសៀមរាប ។

២៨. ទណ្ឌិតឈ្មោះ **ឆយ ឡូញ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ០៥-៣-៩៧ របស់តុលាការខេត្តសៀមរាប ។

២៩. ទណ្ឌិតឈ្មោះ **ឆិត្យ ជារ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ០៥-៣-៩៧ របស់តុលាការខេត្តសៀមរាប ។

៣០. ទណ្ឌិតឈ្មោះ **ព្រឹង ប្រុប** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ១៣-៣-៩៧ របស់តុលាការខេត្តសៀមរាប ។

៣១. ទណ្ឌិតឈ្មោះ **សេង សុភណ្ឌ័** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី ០៨-១០-៩៧ របស់តុលាការខេត្តសៀមរាប ។

៣២. ទណ្ឌិតឈ្មោះ **ម៉ូត សំបាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ១៤-១០-៩៧ របស់តុលាការខេត្តសៀមរាប ។

៣៣. ទណ្ឌិតឈ្មោះ **ម៉ែន ចុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ០៣-៣-៩៨ របស់តុលាការខេត្តសៀមរាប ។

**មាត្រា ៣ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ៣៧ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ :

១. ទណ្ឌិតឈ្មោះ **ខួច គឹមអាន** ហៅ **ធី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥"ក" ចុះថ្ងៃទី ២០-០១-៩៦ របស់តុលាការខេត្តកំពង់ចាម ។

២. ទណ្ឌិតឈ្មោះ **សន អន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២"ក" ចុះថ្ងៃទី ១៥-០២-៩៦ របស់តុលាការខេត្តកំពង់ចាម ។

៣. ទណ្ឌិតឈ្មោះ **សុខ ចំរើន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧"ក" ចុះថ្ងៃទី ០៧-០២-៩៦ របស់តុលាការខេត្តកំពង់ចាម ។

៤. ទណ្ឌិតឈ្មោះ **សាន់ ថុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ០១"ក" ចុះថ្ងៃទី ០៥-០១-៩៦ របស់តុលាការខេត្តកំពង់ចាម ។

៥. ទណ្ឌិតឈ្មោះ **ហូ ផន** ហៅ **គក់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥"ក" ចុះថ្ងៃទី ១៥-៧-៩៦ របស់តុលាការខេត្តកំពង់ចាម ។

៦. ទណ្ឌិតឈ្មោះ **សួស សុគន្ធា** ហៅ **ក្មួក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ០៥-៤-៩៩ របស់តុលាការក្រុងព្រះសីហនុ ។

៧. ទណ្ឌិតឈ្មោះ **ឆៀង ផល្លា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២១-០១-២០០០ របស់តុលាការក្រុងព្រះសីហនុ ។

៨. ទណ្ឌិតឈ្មោះ **គង់ ពៅ** ហៅ **ឌិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២១-០១-២០០០ របស់តុលាការក្រុងព្រះសីហនុ ។

៩. ទណ្ឌិតឈ្មោះ **ចិន អូន** ហៅ **ភារៈ**ហៅ **អាភ្លូន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២១-០១-២០០០ របស់តុលាការក្រុងព្រះសីហនុ ។

១០. ទណ្ឌិតឈ្មោះ **ទ័ត ឆឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ១០-៣-២០០០ របស់តុលាការក្រុងព្រះសីហនុ ។

១១. ទណ្ឌិតឈ្មោះ **គីម សុខា** ហៅ **សឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ០៥-៣-៩៨ របស់តុលាការខេត្តបាត់ដំបង ។

១២. ទណ្ឌិតឈ្មោះ **ឆេព ប៊ុនធឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ០៥-៣-៩៨ របស់តុលាការខេត្តបាត់ដំបង ។

១៣. ទណ្ឌិតឈ្មោះ **ចៅ ប៊ុកកុង** ហៅ **ឌី ហេងសាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី ០៩-៦-៩៧ របស់តុលាការខេត្តបាត់ដំបង ។

១៤. ទណ្ឌិតឈ្មោះ **ឥន សារិន** ហៅ **ពាច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៨០ ចុះថ្ងៃទី ០៨-៤-៩៩ របស់តុលាការខេត្តបាត់ដំបង ។

១៥. ទណ្ឌិតឈ្មោះ **ម៉ៅ ឌុយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣៨ ចុះថ្ងៃទី ២៩-១១-៩៦ របស់តុលាការខេត្តបាត់ដំបង ។

១៦_ ទណ្ឌិតឈ្មោះ **សយ ញារ៉ាញ់** ហៅ **ល្អិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ០៥-០២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

១៧_ ទណ្ឌិតឈ្មោះ **ម៉ង់ ផល្លី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤ ចុះថ្ងៃទី ១៧-៦-៩៥ របស់តុលាការខេត្តស្វាយរៀង ។

១៨_ ទណ្ឌិតឈ្មោះ **នាង ភាព** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ០៩-៤-៩៤ របស់តុលាការខេត្តស្វាយរៀង ។

១៩_ ទណ្ឌិតឈ្មោះ **ជឿង ជឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ២២-៤-៩៧ របស់តុលាការខេត្តសៀមរាប ។

២០_ ទណ្ឌិតឈ្មោះ **កោះ សុខា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ២២-៧-៩៧ របស់តុលាការខេត្តសៀមរាប ។

២១_ ទណ្ឌិតឈ្មោះ **ចាន់ ឃៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ ចុះថ្ងៃទី ១៤-១០-៩៧ របស់តុលាការខេត្តសៀមរាប ។

២២_ ទណ្ឌិតឈ្មោះ **លួន តា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៩ ចុះថ្ងៃទី ២៨-១០-៩៧ របស់តុលាការខេត្តសៀមរាប ។

២៣_ ទណ្ឌិតឈ្មោះ **ថា សុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ០៣-២-៩៨ របស់តុលាការខេត្តសៀមរាប ។

២៤_ ទណ្ឌិតឈ្មោះ **គ្រួច សារ៉ាត់** ហៅ **ញ៉ក សួច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ២៩-៤-៩៨ របស់តុលាការខេត្តសៀមរាប ។

២៥_ ទណ្ឌិតឈ្មោះ **លុន ដារ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ២១-៥-៩៨ របស់តុលាការខេត្តសៀមរាប ។

២៦_ ទណ្ឌិតឈ្មោះ **សយ សល់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ២៦-៥-៩៨ របស់តុលាការខេត្តសៀមរាប ។

២៧_ ទណ្ឌិតឈ្មោះ **ញៀន ពេក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ០៥-៦-៩៨ របស់តុលាការខេត្តសៀមរាប ។

២៨_ ទណ្ឌិតឈ្មោះ **លឿង រិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ ចុះថ្ងៃទី ១៧-៩-៩៨ របស់តុលាការខេត្តសៀមរាប ។

២៩_ ទណ្ឌិតឈ្មោះ **សេក សិទ្ធ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ ចុះថ្ងៃទី ១៧-៩-៩៨ របស់តុលាការខេត្តសៀមរាប ។

៣០_ ទណ្ឌិតឈ្មោះ **ឡាច សុផល** ហៅ **ចក់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី០៥-០១-២០០០ របស់តុលាការខេត្តសៀមរាប ។

៣១_ ទណ្ឌិតឈ្មោះ **ឆេព គោសល្យ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ០៧-៣-២០០០ របស់តុលាការខេត្តសៀមរាប ។

៣២_ ទណ្ឌិតឈ្មោះ **ភុក នី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ ចុះថ្ងៃទី ១០-៣-២០០០ របស់តុលាការខេត្តសៀមរាប ។

៣៣_ ទណ្ឌិតឈ្មោះ **ភុម ម៉ៅល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៣-០២-៩៨ របស់តុលាការខេត្តសៀមរាប ។

៣៤_ ទណ្ឌិតឈ្មោះ **ពៀត ឆយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៨០ ចុះថ្ងៃទី ១៥-៩-៩៨ របស់តុលាការខេត្តសៀមរាប ។

៣៥_ ទណ្ឌិតឈ្មោះ **ភខ ធន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ៦-៧-៩៩ របស់តុលាការខេត្តសៀមរាប ។

៣៦_ ទណ្ឌិតឈ្មោះ **សុខ ទ៉ាន់** ហៅ **យាយណយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ០៩-០២-២០០០ របស់តុលាការខេត្តសៀមរាប ។

៣៧_ ទណ្ឌិតឈ្មោះ **ឆេខ ហុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៣ ចុះថ្ងៃទី ១២-១០-២០០០ របស់តុលាការខេត្តសៀមរាប ។

**មាត្រា ៤ :** ត្រូវបានលើកលែងទោសឱ្យទណ្ឌិតចំនួន ០៨ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះ ខាងក្រោមនេះ :

១_ ទណ្ឌិតឈ្មោះ **សិន សំអាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ១២-៣-៩៨ របស់តុលាការក្រុងព្រះសីហនុ។

២_ ទណ្ឌិតឈ្មោះ **ថៃ ឃន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ ចុះថ្ងៃទី ២៣-១១-៩៨ របស់តុលាការក្រុងព្រះសីហនុ។

៣_ ទណ្ឌិតឈ្មោះ **អៀង ធីរ័ន្ធ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៨-០១-២០០១ របស់តុលាការក្រុងព្រះសីហនុ។

៤_ ទណ្ឌិតឈ្មោះ **គង់ សុភាព** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ ចុះថ្ងៃទី ២៩-៩-៩៩ របស់តុលាការក្រុងព្រះសីហនុ។

៥ - ទណ្ឌិតឈ្មោះ **ឆេន ឈុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ១៦-០៧-២០០១ របស់តុលាការក្រុងព្រះសីហនុ ។

៦ - ទណ្ឌិតឈ្មោះ **ឌិត ឃិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៣ ចុះថ្ងៃទី ២៤-១០-២០០១ របស់តុលាការក្រុងព្រះសីហនុ ។

៧ - ទណ្ឌិតឈ្មោះ **កើត សារី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ២៧-១១-៩០ របស់តុលាការខេត្តស្វាយរៀង ។

៨ - ទណ្ឌិតឈ្មោះ **នៅ គប** ហៅ **ម៉ាប់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១៨-១១-៩៩ របស់តុលាការខេត្តសៀមរាប ។

**មាត្រា ៥ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ១៣១ច.ល

៣រល-០២.០៥-០០១៥១

*ផ្ញើទៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី២៤ខែឧសភាឆ្នាំ ២០០២*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៤២

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចាង ជិនហូ** (CHANG JIN HO) សញ្ជាតិដើមសាធារណរដ្ឋកូរ៉េ កើតថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៥២ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរយកឈ្មោះថ្មី **ចាន់ សំរេច** (CHAN SAMRACH) ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ១៣៤ ច.ល

៣រស.០២.០៥.០០១៥២

*ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ. ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០២*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារិ៍ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៤៣

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញសេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** ដាក់ឱ្យឯកឧត្តម **ធឹក គ្រឿនថុត្ថា** អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន ចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ តែនៅបន្តការងារក្នុងមុខដំណែងនយោបាយដដែល រហូតដល់មានការសំរេចជាថ្មី ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ១៣៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

៣រល-០៥.០៥-០០១៥៣

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០២*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.០០០ លានរៀល ( បួនពាន់លានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់ ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកខាងលើនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

BBNIII C Sub- Degree

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតំឡើងប្រព័ន្ធហិរញ្ញកិច្ច សំរាប់ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋគុយបា និង ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់មន្ត្រីរាជការបំពេញភារកិច្ចនៅក្រៅប្រទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១:** ត្រូវបានតំឡើងប្រព័ន្ធហិរញ្ញកិច្ចពីប្រភេទ " **គ** " មកប្រភេទ " **ខ** " សំរាប់ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋគុយបា និង ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញ។

**មាត្រា ២ :** ត្រូវបានទុកជានិរាករណ៍ នូវ **មាត្រា ២** ត្រង់ចំនុច **គ/១** - **គ/២** - និង **គ/៦**- ដែលបានចែងក្នុងអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់មន្ត្រីរាជការបំពេញភារកិច្ចនៅក្រៅប្រទេស ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៤ :** អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០២ តទៅ ។

ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យ

ប្រើច្បាប់ភូមិបាល

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាព ពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

## ស ំ រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០០ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ត្រូវបានចាត់ទុកជានិរាករណ៍ ហើយត្រូវបានជំនួសដោយអនុក្រឹត្យនេះ ដែលកំណត់នីតិវិធី នៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីតាមរយៈការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធ នៅក្នុងតំបន់ដែលបានប្រកាសថាជាទីតាំងធ្វើការវិនិច្ឆ័យដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ។

**មាត្រា ២ .-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ និងណែនាំបច្ចេកទេសជំនាញ និងទំរង់បែបបទនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

អភិបាលខេត្ត ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

## ជំពូកទី ២
## សមត្ថកិច្ច និង ភារកិច្ច

**មាត្រា ៣ .-**

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសំរាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលមាន ៖

-តំណាងអភិបាលខេត្ត ក្រុង ជាប្រធាន

-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក

-មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក

-អភិបាលស្រុក ខណ្ឌ ឬតំណាង ជាសមាជិក

-មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក

-មេភូមិ ឬតំណាង ជាសមាជិក

-ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ៣រូប ជាសមាជិក ។

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន ៖

-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី

-ទទួលរាល់បណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង

-ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ

-លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៤ .-**

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យព្រមទាំងមន្ត្រីចាំបាច់មួយចំនួនទៀតរួមមាន ៖ មន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និងមន្ត្រីវាស់វែង ដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្តីណែនាំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិដឹកនាំចេញសេចក្តីណែនាំចាំបាច់ដល់មន្ត្រីជំនាញ ដែលបានតែងតាំងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៤ នៃអនុក្រឹត្យនេះ ។

មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែងមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងព្រំនៃក្បាលដីណាមួយ ។

មន្ត្រីវិនិច្ឆ័យ មានសិទ្ធិសាកសួរយកពត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងការវិនិច្ឆ័យ ។

**មាត្រា ៥ .-**

ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងការវិនិច្ឆ័យ ដោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឯកសារ ឬភស្តុតាងផ្សេងៗដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារ នៃការវិនិច្ឆ័យ និងមានសិទ្ធិសុំឱ្យមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារ នៃទិន្នន័យដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ ។

**មាត្រា ៦ .-**

អភិបាលខេត្ត ក្រុង ត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងហោចណាស់ ១៥(ដប់ប្រាំ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ។

អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងជាសាធារណៈ អំពីពេលវេលា និងទីកន្លែង នៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្តីជូនដំណឹងត្រូវបិទឱ្យសាធារណៈជនដឹងយ៉ាងហោច ៧(ប្រាំពីរ) ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយ ក្នុងកន្លែងដែលងាយឃើញនៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់ ។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ញាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យ ដែលបានលើកឡើង ។

កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋាន ចាត់ទុកថាជាការចាំបាច់ ។

**មាត្រា ៧ .-**

មន្ត្រីកំណត់ព្រំដី ត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន ៧(ប្រាំពីរ) ថ្ងៃ យ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមក ចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង ។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី ។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដី ត្រូវគោរពគោលការណ៍ ដូចខាងក្រោម ៖

ក- បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង ។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច( ក) នៃមាត្រានេះ មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដី តាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬចំលើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី ។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដី ត្រូវកំណត់ដោយអនុលោមទៅតាមចំណុច( ក) ឬ( ខ) នៃវាក្យខ័ណ្ឌទី ២ មាត្រា ៧ នៃអនុក្រឹត្យនេះ ។

ឃ-វិវាទទាំងអស់ អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសំរុះសំរួល និងដោះស្រាយវិវាទក្រោមមាត្រា ១២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៨ .-**

មន្ត្រីវាស់វែងដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែង ដែលជាតម្រូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិច្ឆ័យ

**មាត្រា ៩ .-**

មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងពត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗ ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនេះ ចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

**មាត្រា ១០ .-**

ការរៀបចំឯកសារនៃការវិនិច្ឆ័យមានន័យដូចខាងក្រោម :

១- ឯកសារនៃការវិនិច្ឆ័យត្រូវមាន :

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះម្ចាស់ដី

-ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។ ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីនីមួយៗ ត្រូវបង្ហាញ :

ក- អត្តសញ្ញាណក្បាលដី

ខ- អត្តសញ្ញាណម្ចាស់ដី

គ- កាលបរិច្ឆេទនៃការវិនិច្ឆ័យ ។

២- ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវផ្តិតមេដៃយល់ព្រមពីម្ចាស់ដី ព្រមទាំងអ្នកជាប់ព្រំ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីវិនិច្ឆ័យ ។

៣- នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ ។

## មាត្រា ១១ .-

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវមានរយៈវេលា ៣០(សាមសិប)ថ្ងៃ នៅកន្លែងដែលងាយមើលឃើញ សំរាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

អាជ្ញាធរខេត្ត ក្រុង ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល ។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ អាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណា ដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់ នៃជនណាមួយ ។ ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបាន ដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

## មាត្រា ១២ .-

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយ ដែលបានចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន ។

ក្រោយពីផ្តល់នូវការកត់សំគាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់ គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង ។

ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ស្របតាមនីតិវិធី ដែលនឹងកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

**មាត្រា ១៣ .-**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ គណៈកម្មការរដ្ឋបាល ត្រូវផ្តល់ការយល់ព្រមលើឯកសារនៃការវិនិច្ឆ័យចំពោះក្បាលដីទាំងឡាយណាដែលមិនមានទំនាស់ ។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនទៅអភិបាលខេត្ត ក្រុង ចុះហត្ថលេខា ។

**មាត្រា ១៤ .-**

ក្រោយពីអភិបាលខេត្ត ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាហើយ ឯកសារនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីដែលមិនមានទំនាស់ ។ ចំពោះឯកសារនៃការវិនិច្ឆ័យ ដែលនៅពាក់ព័ន្ធនឹងវិវាទ នឹងត្រូវបញ្ចប់ជាស្ថាពរ នៅពេលមានការដោះស្រាយចប់សព្វគ្រប់ដោយគណៈកម្មការសុរិយោដី ឬដោយតុលាការ ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរយោងតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ឯកសារនៃការវិនិច្ឆ័យព្រមទាំងឯកសារទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដី ដើម្បី ចុះបញ្ជី។

ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យ ត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លើគ្រប់ក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យនេះ ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត ក្រុងណាដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៃខេត្ត ក្រុងរបស់ខ្លួន ។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារផ្សេងៗ នឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត ក្រុង

-ដូចមាត្រា ១៦

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

## ស ំ រ េ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ..**

អនុក្រឹត្យនេះ មានគោលដៅកំណត់វចនាសម្ព័ន្ធ បេសកកម្ម និង មុខងារ របស់គណៈកម្មការសុរិយោដី ។

**មាត្រា ២ ..**

អនុក្រឹត្យនេះអនុវត្តចំពោះវិវាទ ដែលទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី ។ ក្នុងករណីនេះ គណៈកម្មការសុរិយោដីមានសិទ្ធិសំរេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់ ។

## ជំពូកទី ២
## វចនាសម្ព័ន្ធ និង បេសកកម្ម

**មាត្រា ៣ ..**

គណៈកម្មការសុរិយោដី ត្រូវមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ដូចតទៅ :

១.-វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ

២.-វិវាទ ដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល ។

**មាត្រា ៤ ..**

គណៈកម្មការសុរិយោដី មានវចនាសម្ព័ន្ធដូចតទៅ :

១.-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ថា **គ.ស.ស.ខ** មានទីតាំងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

២.-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ថា **គ.ស.ខ.ក** មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

៣.-គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានអក្សរកាត់ថា **គ.ស.ជ** មានទីតាំងនៅក្នុងទីស្តីការក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋាន ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

## ជំពូកទី ៣
## គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៥ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិក ។

ប្រធានគណៈកម្មការនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និង ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក ។

**មាត្រា ៦ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ ។ ការសម្រុះសម្រួលវិវាទ ត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី ។

## ជំពូកទី ៤
## ការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៧ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទំរង់បែបបទនៃពាក្យបណ្តឹង ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃវិវាទដែលបានទទួល ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថាតើភាគីវិវាទយល់ព្រមធ្វើការដោះស្រាយសម្រុះសម្រួលតាមនីតិវិធីនេះឬទេ ។

**មាត្រា ៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើវិវាទ ។ ការស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដី ដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និងការប្រមូលឯកសារ ដែលមានចម្លើយរបស់សាក្សី និងពត៌មានទាក់ទងនឹងក្បាលដីមានវិវាទ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះ សំរាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកសាង និង បញ្ចូលឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ។

**មាត្រា ៩ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវសម្រុះសម្រួលវិវាទក្រៅពីករណី ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

ការសម្រុះសម្រួលត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ១០ ..**

បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ចំពោះករណីដូចតទៅ :

(១) ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភោគីតូចតាចមួយចំនួនដែរ ។

(២) ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់ ។

(៣) ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

(៤) វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

**មាត្រា ១១ ..**

ប្រសិនបើការដោះស្រាយអាចសំរេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ហើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌមួយច្បាប់ ដើម្បីចាប់ផ្តើមដំណើរការ

អនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

## ជំពូកទី ៥
## គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

**មាត្រា ១២ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

-អភិបាល ឬ អភិបាលរងខេត្ត ក្រុង ជាប្រធាន

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង អាចអញ្ជើញតំណាងស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្ត ក្រុង ដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៣ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានភារកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា ១០ និង មាត្រា ១១ វាក្យខ័ណ្ឌទី ២ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**មាត្រា ១៤ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានមុខងារ ភារកិច្ចដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង រាល់ពាក្យបណ្ដឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ក្នុងករណីការសម្រុះសម្រួលបានសំរេច ត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៦

## ការសម្រុះសម្រួលនៅថ្នាក់ខេត្ត ក្រុង

**មាត្រា ១៥ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ពុំមានសិទ្ធិសំរេចលើករណីវិវាទណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង សំណុំរឿងវិវាទនេះ ត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**មាត្រា ១៦ ..**

ប្រសិនបើការសម្រុះសម្រួលអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីចាប់ផ្ដើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួល ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## ជំពូកទី ៧
## គណៈកម្មការសុរិយោដីថ្នាក់ជាតិ

**មាត្រា ១៧ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមាសភាពដូចខាងក្រោម :

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក

-រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ឱ្យមកចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្តីសំរេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា ១៦ និងវិវាទដែលមានចែងក្នុងចំណុចទី ២ នៃមាត្រា ៣ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**មាត្រា ១៩ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

លេខាធិការដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវ

តែងតាំងដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានតួនាទីដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៨
## ការដោះស្រាយនៅថ្នាក់ជាតិ

### មាត្រា ២០ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសំរេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់ ។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅតុលាការ ដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

### មាត្រា ២១ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលទាក់ទងនឹងវិវាទ ហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរៀបចំបើកសវនាការមុនពេលធ្វើសេចក្តីសំរេចលើវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទ តាមការស្នើសុំរបស់ភាគីណាមួយ ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយ នោះភាគីផ្សេងៗទៀត មានសិទ្ធិទទួលបានការជូនដំណឹងជាមុន អំពីការពិគ្រោះយោបល់នេះ ដើម្បីមានវត្តមានទៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់ ។

**មាត្រា ២២ ..**

សេចក្ដីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្ដីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្ដីសំរេច ។

**មាត្រា ២៣ ..**

ភាគីវិវាទ មានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្ដឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្ដីសំរេច ។

ប្រសិនបើតុលាការបញ្ជូនរឿងក្ដីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្ដល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដី ត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្នែកច្បាប់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្ដឹង ទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ លេខាធិការដ្ឋាន ត្រូវធានាការពារសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីចំពោះតុលាការ ។

តុលាការ ត្រូវធ្វើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ មកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី ។

ប្រសិនបើគ្មានបណ្ដឹងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះ នោះសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចាត់ទុកជាស្ថាពរ ។

## ជំពូកទី ៩
## ការចុះបញ្ជី

**មាត្រា ២៤ ..**

បន្ទាប់ពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបាន គណៈកម្ម-ការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្តីសំរេចនោះ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់ ។

## ជំពូកទី ១០
## បទប្បញ្ញត្តិរដ្ឋបាល

**មាត្រា ២៥ ..**

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះ ត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ។ ប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើជាប្រធានអាដហុក ដើម្បីដោះស្រាយករណីវិវាទនេះ ។

**មាត្រា ២៦ ..**

ជនដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិករ ឬភោគីស្របច្បាប់ នៃក្បាលដី ដែលមានវិវាទក្រោមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវានៃការចុះបញ្ជីក្បាលដី អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល។

**មាត្រា ២៧ ៈ**

ភាគីវិវាទ ត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផល អំពីការប្រជុំដើម្បីសម្រុះសម្រួល ឬសំរេចលើវិវាទក្រោមអនុក្រឹត្យនេះ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីជួយខ្លួន ក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីធ្វើជាតំណាងរបស់ខ្លួន ក្នុងពេលប្រជុំធ្វើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដី ។

ភាគីវិវាទ មានសិទ្ធិបង្ហាញភស្តុតាងផ្ទាល់មាត់ ឬឯកសារជាក់ស្តែងដែលទាក់ទងនឹងវិវាទ ដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ ។

គណៈកម្មការសុរិយោដី ត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងភស្តុតាងជាក់ស្តែងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ អំពីវិវាទ ។ ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទ ត្រូវបានបើកឱ្យភាគីពាក់ព័ន្ធពិនិត្យ ។

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអមដោយរបាយការណ៍ស្តីពីដំណើររឿង និងដំណើរការដោះស្រាយវិវាទ ដែលផ្អែកលើភស្តុតាងទាំងឡាយ ដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ដែលជាផ្នែកនៃឯកសារផ្លូវការ ។

ច្បាប់ចម្លងនៃសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱ្យភាគី វិវាទនីមួយៗ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ២៨ ៈ**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ១១

## ប្រភពធនធាន

**មាត្រា ២៩ ..**

គណៈកម្មការសុរិយោដី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣០ ..**

ប្រភពធនធាន និងថវិកា របស់គណៈកម្មការសុរិយោដី ត្រូវបានផ្តល់ដោយ :

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេសក្រៅ ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ១២

## អវសានប្បញ្ញត្តិ

**មាត្រា ៣១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

__កន្លែងទទួល:__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

## ស ំ រ េ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់នីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ដែលមិនទាន់បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។

## ជំពូកទី ២

## ភារកិច្ច និង ភារពូកិច្ច

**មាត្រា ២ .-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចណែនាំ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តអនុក្រឹត្យនេះ ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវកំណត់ស្តង់ដារបច្ចេកទេសសំរាប់ការកំណត់ព្រំដី ការកសាងប្លង់សុរិយោដី និងការកសាងឯកសារផ្សេងៗ ព្រមទាំងកំណត់គំរូឯកសារ ដែលត្រូវប្រើក្នុងនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ។

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រាល់ក្បាលដី ដែលស្នើសុំចុះបញ្ជីក្រោមអនុក្រឹត្យនេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌណាមួយ មិនអាចបំពេញតាមល័ក្ខខណ្ឌសំរាប់ការចុះបញ្ជីក្រោមអនុក្រឹត្យនេះ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយសារតែសមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខណ្ឌនោះ អាចស្នើសុំអោយរដ្ឋបាលសុរិយោដីខេត្ត ក្រុង ជួយដល់ការអនុវត្តនូវការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

មាត្រា ៣ .-

មន្ត្រីទទួលបន្ទុកការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ នៅពេលធ្វើការអង្កេតវាស់វែង និងអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដី ឬសិទ្ធិលើក្បាលដី ។

មាត្រា ៤ .-

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកងកំលាំងប្រដាប់អាវុធ ឱ្យជួយជ្រោមជ្រែងក្នុងការអនុវត្តការងារវាស់វែង ។

មាត្រា ៥ .-

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាង ដែលទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ តាមសំណូមពររបស់មន្ត្រីទទួលបន្ទុក ។

ក្នុងពេលចុះកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ក្នុងករណីអវត្តមានអ្នកដាក់ពាក្យ ឬតំណាងស្របច្បាប់ ការកំណត់ព្រំក្បាលដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន ឬ/និងភស្តុតាងដែលមានលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ដែលទាក់ទងនឹងព្រំដី ។

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ត្រូវទទួលការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

មាត្រា ៦ .-

ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួមសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗ តាមសំណូមពររបស់មន្ត្រីទទួលបន្ទុក ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ។

## ជំពូកទី ៣

## អំពីនីតិវិធីនៃការចុះបញ្ជីដី

**មាត្រា ៧ .-**

សាមីអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីតាមគំរូដែលបានកំណត់ មករដ្ឋបាលសុរិយោដីស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

ពាក្យស្នើសុំត្រូវមាន :

- ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យ
- ការពិពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ
- ការពិពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី
- ឯកសារ ឬ/និងភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ។

**មាត្រា ៨ .-**

ពាក្យស្នើសុំត្រូវបានពិនិត្យដោយរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ផ្អែកតាមឯកសារដែលមាន និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជី ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវកត់ត្រាចូលក្នុងសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចារលើពាក្យ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចអនុវត្តនីតិវិធីនៃការចុះបញ្ជីបាន ។ អ្នកដាក់ពាក្យមានសិទ្ធិប្តឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

ក្នុងករណីពិនិត្យឃើញថា មានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទនោះទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ តាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

**មាត្រា ៩ .-**

អភិបាលស្រុក ខណ្ឌ ត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី ទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេល ១៤(ដប់បួន)ថ្ងៃយ៉ាងតិចមុនកាលបរិច្ឆេទ នៃការកំណត់ព្រំដី នៅសាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។



៥

**មាត្រា ១០ .-**

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែង ត្រូវកំណត់ព្រំក្បាលដីដែលស្នើសុំចុះបញ្ជី តាមពេលវេលាដែលបានជូនដំណឹងដោយយោងតាមសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំរបស់រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ។

នៅពេលធ្វើការកំណត់ព្រំក្បាលដី មន្ត្រីទទួលបន្ទុកត្រូវពិនិត្យឯកសារដែលមាន ភស្តុតាង និងពតិមានជាលាយលក្ខណ៍អក្សរ និងពតិមានផ្ទាល់មាត់ផ្សេងៗ ដែលទាក់ទងនឹងព្រំប្រទល់ក្បាលដី ដែលស្នើសុំចុះបញ្ជី ហើយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម :

ក-ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង ។

ខ-ក្នុងករណីម្ចាស់ដីជាប់ព្រំ មិនមានវត្តមាន ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាងដែលជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងភស្តុតាំងផ្ទាល់មាត់ ដែលទាក់ទងនឹងព្រំដីនោះ ។

គ-ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីស្ថិតនៅជាប់នឹងដីសាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច(ក) ឬ(ខ)ខាងលើ ។

វិវាទអំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ តាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី ។

ការវាស់វែង ត្រូវធ្វើក្រោយពីបានកំណត់ព្រំក្បាលដីរួច ។

**មាត្រា ១១ .-**

មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវអង្កេតលើឯកសារដែលមាន ភស្តុតាង និងពតិមានជាលាយល័ក្ខណ៍អក្សរ និងពតិមានផ្ទាល់មាត់ទាក់ទងនឹងសិទ្ធិលើក្បាលដី ដែលស្នើសុំចុះបញ្ជី ។

ចំពោះដីភោគៈ ការវិនិច្ឆ័យត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម :

ក-ដីដែលស្នើសុំចុះបញ្ជី ត្រូវតែបានកាន់កាប់មុនថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១

ខ-ដីដែលស្នើសុំចុះបញ្ជី ត្រូវបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ :

-ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ហើយចំណុចព្រំក្បាលដី មាននិយាមការច្បាស់លាស់ អាចត្រូវបានស្នើផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីនោះ

- ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ប៉ុន្តែចំណុចព្រំក្បាលដី មិនទាន់មាននិយាមការច្បាស់លាស់ អាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ

- ក្នុងករណីកាន់កាប់តិចជាងប្រាំឆ្នាំ អាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ ។

អចលនវត្ថុរបស់រដ្ឋ ត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិសាធារណៈ ឬជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ស្របតាមបទប្បញ្ញត្តិនៃជំពូកទី ២ នៃច្បាប់ភូមិបាល ។

## មាត្រា ១២ .-

ផ្អែកតាមការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវរៀបចំឯកសារ នៃការវិនិច្ឆ័យ រួមមាន ៖

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី

-ផែនទីក្បាលដី និងគំនូសបង្ហាញទីតាំងដី

-បញ្ជីឈ្មោះម្ចាស់ក្បាលដីដែលស្នើសុំចុះបញ្ជី ។

ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី កម្មសិទ្ធិករ ឬភោគីកាលបរិច្ឆេទនៃការកាន់កាប់ដី កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រាល់សិទ្ធិ និងបន្ទុកដែលមានលើក្បាលដីដូចមានចែងក្នុងច្បាប់ភូមិបាល ។

ផែនទីក្បាលដីដែលស្នើសុំចុះបញ្ជី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី រួមមាន លេខក្បាលដី រូបរាងក្បាលដី លេខក្បាលដី ឬ/និងឈ្មោះម្ចាស់ក្បាលដីជាប់ព្រំ ។

បញ្ជីឈ្មោះម្ចាស់ដីនៃក្បាលដីដែលស្នើសុំចុះបញ្ជី បង្ហាញអំពីឈ្មោះ សារពើ ប្រភេទទ្រព្យរបស់កម្មសិទ្ធិករ ឬភោគីនៃក្បាលដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ ទំហំ និងរូបភាពប្រើប្រាស់ដី ។

## មាត្រា ១៣ .-

បន្ទាប់ពីការពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទ នៃការប្រមូលទិន្នន័យក្បាលដី ។

ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយរួមមាន ផែនទីក្បាលដី គំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី ។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ នៅសាលាស្រុក ខណ្ឌដែលមានសមត្ថកិច្ច ។ សេចក្តីថតចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរ នៅទីស្នាក់ការឃុំ សង្កាត់ ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

អភិបាលស្រុក ខណ្ឌ ត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យនេះដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី ។ សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច ៧(ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ នៅសាលាឃុំ សង្កាត់ និងនៅសាលាស្រុក ខណ្ឌ ។

**មាត្រា ១៤ .-**

ក្នុងរយៈពេលនៃការផ្សព្វផ្សាយ ជនដែលមានផលប្រយោជន៍ទាក់ទងនឹងក្បាលដីស្នើសុំចុះបញ្ជី អាចជូនដំណឹងអំពីការជំទាស់របស់ខ្លួនទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្នុងករណីពិនិត្យ ឃើញថាឯកសារនៃការវិនិច្ឆ័យ ដែលបានបិទផ្សាយជាសាធារណៈ មានលក្ខណៈមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ។ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងពត៌មានទាំងអស់ ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈសមហេតុផល រដ្ឋបាលសុរិយោដីស្រុក ខណ្ឌអាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់នៃជនណាមួយ ។

ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈមិនសមហេតុផល ការជំទាស់ត្រូវបានដាក់ឱ្យធ្វើការសម្រុះសម្រួល និងដោះស្រាយតាមនីតិវិធី ដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី ។

**មាត្រា ១៥ .-**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវបញ្ចូលក្បាលដីទៅក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ ។

ផែនទីមានលក្ខណៈដាច់ដោយដុំគឺជាប្លង់សុរិយោដីដែលបង្ហាញអំពីទីតាំង លេខ និងព្រំប្រទល់នៃក្បាលដីទាំងឡាយដែលបានចុះបញ្ជីរួច និងក្បាលដីដែលស្នើសុំចុះបញ្ជី បន្ទាប់ពីបានបិទផ្សាយជាសាធារណៈ និងបានបញ្ចប់ការសម្រុះសម្រួល និងការដោះស្រាយទំនាស់ ។

**មាត្រា ១៦ .-**

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវផ្ញើសំណុំឯកសារទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដូចមានខាងក្រោម :

- ពាក្យស្នើសុំចុះបញ្ជីដី
- ឯកសារនៃការវិនិច្ឆ័យ
- សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ
- សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈ

- របាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ
- ពាក្យបណ្ដឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន
- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន
- កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន ។

ក្នុងករណីដែលពិនិត្យឃើញថាឯកសារទាំងនោះគ្រប់គ្រាន់ និងត្រឹមត្រូវហើយ រដ្ឋបាលសុរិយោដីខេត្ត ក្រុង ត្រូវចុះហត្ថលេខា រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល ។

**មាត្រា ១៧ .-**

ក្បាលដីត្រូវបានចុះបញ្ជី នៅពេលដែលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឬរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកត់ត្រារួចហើយក្នុងសៀវភៅគោលបញ្ជីដី ។

**មាត្រា ១៨ .-**

បន្ទាប់ពីក្បាលដីត្រូវបានចុះបញ្ជីរួច រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុឱ្យកម្មសិទ្ធិករនៃក្បាលដីដែលបានចុះបញ្ជី ឬបណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឱ្យភោគីដែលបានចុះបញ្ជី ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត ក្រុងណា ដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។

**មាត្រា ១៩ .-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវបញ្ជូនតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុងដែលមិនទាន់បានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ហើយបញ្ជូនតារាងនេះបន្តទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នាដែរ ។

រដ្ឋបាលសុរិយោដីខេត្ត ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្ញើតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ និងផ្ញើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារផ្សេងៗ ត្រូវកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ២០ .-**

សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ចក្នុងការអនុវត្តអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរួម អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ២២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលមាត្រា ១ និងមាត្រា ៣ វាក្យខ័ណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាយោធា

✦✦✦✦✦

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា ១.-**

ត្រូវបានកែសំរួលមាត្រា ១ និងមាត្រា ៣ វាក្យខ័ណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា ដែលមានខ្លឹមសារដូចតទៅ :

**មាត្រា ១ថ្មី.-** បង្កើតក្រុមប្រឹក្សាយោធាមួយ ដោយអនុលោមតាមមាត្រា ២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ហើយដែលមានសមាសភាព ៖

- រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន
- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធានអចិន្ត្រៃយ៍
- អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ សមាជិក
- អនុរដ្ឋលេខាធិការក្រសួងការពារជាតិ មួយរូប សមាជិក
- នាយរងសេនាធិការចំរុះ មួយចំនួន សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងកងទ័ពជើងគោក កងទ័ពជើងអាកាស កងទ័ពជើងទឹក និងកងរាជអាវុធហត្ថ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអគ្គនាយកដ្ឋានទាំងបី នៃក្រសួងការពារជាតិ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអោយស្ថាប័ន អធិការកិច្ច អយ្យការយោធា តុលាការយោធា វិទ្យាស្ថានយោធាកម្ពុជា ខុទ្ទកាល័យ ក្រសួងការពារជាតិ ទីចាត់ការហ៊ឹកហ្វឺន ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន សមាជិក
- នាយទាហានជាន់ខ្ពស់មួយរូបៗ តំណាងអោយគ្រប់យោធភូមិភាគ និងបណ្តាកងពលចំណុះអគ្គបញ្ជាការ សមាជិក
- នាយក នាយកដ្ឋាននីតិកម្មក្រសួងការពារជាតិ លេខាធិការ
- នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ លេខាធិការរង
- នាយក ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ លេខាធិការរង

**មាត្រា ៣ថ្មី.-** ក្រុមប្រឹក្សាយោធា ត្រូវប្រជុំពិនិត្យស្រាវជ្រាវ និងប្រជុំពេញអង្គ ៖

- ការប្រជុំពិនិត្យស្រាវជ្រាវប្រព្រឹត្តទៅក្រោមអធិបតីភាពនៃតំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអាចអញ្ជើញបន្ថែមសមាសភាពដែលមានការពាក់ព័ន្ធចូលរួម
- ការប្រជុំពេញអង្គ ដើម្បីធ្វើសេចក្តីសំរេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រី ក្រសួងការពារជាតិ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- អគ្គបញ្ជាការដ្ឋាន
- ដូចមាត្រា ១ និង២
- កាលប្បវត្តិ-ឯកសារ

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ទៀ បាញ់**

**ស៊ីសុវត្ថិ សិរីរ័ត្ន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១៥៧ អនក្រ.ទក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ៤៨ រូប ដែលបានបរិច្ចាគធនធាន ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា ក្នុងស្រុកសំរោង ខេត្តតាកែវ ដូចមាននាមនិងទឹកប្រាក់ខាងក្រោម ÷

### ក-មេដាយមាសស្ថាបនាជាតិ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ម៉ុក | ម៉ារ៉េត | ថវិកា ១៦.០០០ USD |
| ២-លោកឧត្តមសេនិយ | ស្រ៊ុន | សារឿន | ថវិកា ១២.០០០ USD |
| ៣-លោកវរសេនិយ | ផូ | ខន | ថវិកា ១៧.០០០ USD |
| ៤-ព្រះតេជគុណ | អ៊ុន | សារឿន | ថវិកា ១២.០០០ USD |
| ៥-ព្រះតេជគុណ | ម៉ែន | ស៊ុម | ថវិកា ១២.០០០ USD |
| ៦-ព្រះតេជគុណ | មាស | ម៉ុនសំ | ថវិកា ១២.០០០ USD |
| ៧-ព្រះតេជគុណ | កែវ | ស្រ៊ីច | ថវិកា ១២.០០០ USD |
| ៨-ព្រះតេជគុណ | មាស | ចែម | ថវិកា ១២.០០០ USD |
| ៩-ព្រះតេជគុណ | អេម | សុន | ថវិកា ១៣.០០០ USD |

| | | | |
|---|---|---|---|
| ១០-ព្រះតេជគុណ | ធីវ | ឈិន | ថវិកា ១២.៥០០ USD |
| ១១-ព្រះតេជគុណ | សោ | គុយ | ថវិកា ១២.០០០ USD |
| ១២-ព្រះតេជគុណ | ប៊ុន | លឹម | ថវិកា ១២.០០០ USD |
| ១៣-ឯកឧត្តម | លី | ណារុន | ថវិកា ១០.០០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | ផែង | គីម | ថវិកា ៦.០០០ USD |
| ២-ព្រះតេជគុណ | គង់ | សុត | ថវិកា ៦.០០០ USD |
| ៣-ព្រះតេជគុណ | ឡៀវ | ជារ៉ា | ថវិកា ៧.០០០ USD |
| ៤-ព្រះតេជគុណ | ឯម | បូរ៉ា | ថវិកា ៦.០០០ USD |
| ៥-លោក | អ៊ូ | ស៊ុនហ៊ាន់ | ថវិកា ៧.០០០ USD |
| ៦-លោក | ឈរ | ចាណាត | ថវិកា ៧.០០០ USD |
| ៧-លោក | ហេង | ណារ៉េត | ថវិកា ៨.០០០ USD |
| ៨-លោកស្រី | ជូ | សុខផានី | ថវិកា ៦.០០០ USD |
| ៩-លោក | សែន | ស៊ុជារា | ថវិកា ៦.០០០ USD |
| ១០-លោក | ឆ៊ាន់ | បូណុច | ថវិកា ៦.០០០ USD |
| ១១-លោក | ចាយ | សាមិត្ត | ថវិកា ៧.០០០ USD |
| ១២-លោក | សំ | ចំរើន | ថវិកា ៦.០០០ USD |
| ១៣-លោក | ជា | ស៊ុណា | ថវិកា ៦.០០០ USD |
| ១៤-លោក | គល់ | ចន្ថុនា | ថវិកា ៦.០០០ USD |
| ១៥-លោក | ឆា | ជុប | ថវិកា ៦.០០០ USD |
| ១៦-លោក | ឡុញ | ហ៊ែល | ថវិកា ៦.០០០ USD |
| ១៧-លោក | ខូន | គង់ | ថវិកា ៦.០០០ USD |
| ១៨-លោក | គុច | សុខាន | ថវិកា ៦.០០០ USD |
| ១៩-លោក | គុច | ឃី | ថវិកា ៦.០០០ USD |
| ២០-លោក | នៅ | យ៉ន | ថវិកា ៦.០០០ USD |
| ២១-លោក | ផាំង | ឡូត | ថវិកា ៦.០០០ USD |
| ២២-លោក | សៅ | ណែម | ថវិកា ៦.០០០ USD |
| ២៣-លោក | ហេង | ឈន | ថវិកា ៦.០០០ USD |
| ២៤-លោក | ឯក | ណុប | ថវិកា ៦.០០០ USD |

| | | | |
|---|---|---|---|
| ២៥-លោក | ម៉ុំ ហ៊ាង | ថវិកា | ៦.០០០ USD |
| ២៦-លោក | ហម សឹង | ថវិកា | ៦.០០០ USD |
| ២៧-លោក | ឆិត គង់ | ថវិកា | ៦.០០០ USD |
| ២៨-លោក | អ៊ុក ឈួន | ថវិកា | ៥.៨០០ USD |
| ២៩-លោក | ជាញ់ សោភ័ណ្ឌ | ថវិកា | ៥.៨០០ USD |
| ៣០-លោក | ភី ស្មើង | ថវិកា | ៥.៦០០ USD |
| ៣១-លោក | ង៉ែត សឿ | ថវិកា | ៥.៥០០ USD |
| ៣២-លោក | ឃិត សរំ | ថវិកា | ៥.៥០០ USD |

**គ_មេជាយសីវត្ថស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | នុត ថុល | ថវិកា | ៣.៥០០ USD |
| ២-លោក | ឈឹម ទើន | ថវិកា | ៣.៨០០ USD |
| ៣-លោក | ជូន សាក់ | ថវិកា | ៣.៦០០ USD |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៥៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងនិងសម្រួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ថៃ ចណ្ណា** បច្ចុប្បន្នប្រធាននាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ានៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាលេខាផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាឋានៈថ្នាក់ប្រធាននាយកដ្ឋាន ដដែល ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ហ្វូត ផល** អតីតឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជាប្រធាននាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំនួសលោក **ថៃ ចណ្ណា** ។

**មាត្រា ៣ :** អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងមន្ត្រីរាជការ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៥៥ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយការងារ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការចំនួន ០២ រូប ដែលមានស្នាដៃល្អ ក្នុងការអនុវត្តគំរោងស្តារស្ថានីយ៍វារីអគ្គិសនី គីរីរម្យ១ និង ខ្សែបញ្ជូន 115 KV គីរីរម្យ - ភ្នំពេញ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក.មេដាយមាសការងារ :**

-ឯកឧត្តម **ទី នរិន្ទ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ( អតីតអគ្គនាយករងអគ្គិសនីកម្ពុជា)

**ខ.មេដាយប្រាក់ការងារ :**

-លោក **ស៊ុន ប៊ុណ្ណា** អនុប្រធានក្បាលរួមការិយាល័យគ្រប់គ្រង គំរោងឯកជន នៃអគ្គិសនីកម្ពុជា

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៥៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនប្រធាន និង អ្នកឯកទេសនៃក្រុមហ៊ុន CETIC ចំនួន ០៣ រូប ដែលបានសហការល្អប្រសើរ ក្នុងការអនុវត្តគំរោងស្តារស្ថានីយ៍វារីអគ្គិសនីគីរីរម្យ១ និង ខ្សែបញ្ជូន 115 KV គីរីរម្យ - ភ្នំពេញ ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយសហមេត្រី** ថ្នាក់ **សេនា :**

- លោក **MICHAEL JINGZHONG ZHANG CEO & President of CETIC International Hydro-Power Development Company, Ltd.**

**ខ-មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ :**

- លោក **FUYUAN HE Chief Engineer & Chief Supervisor of CETIC International Hydro-Power Development Company, Ltd.**
- លោក **ZHONGREN SI Deputy Chief Supervisor ( Transmission ) of CETIC International Hydro-Power Development Company, Ltd.**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា — ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៥៧ អនក្រ.តក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

### សំ រេ ច

**មាត្រា១** : ត្រូវបានតែងតាំងលោក **ចាប សុជារិទ្ធ** ជាប្រធាននាយកដ្ឋានអាស៊ាន នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤២៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបសអភិបាលខេត្តកំពង់ចាម

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **ហាក់ ថុល** ដែលបានចំណាយថវិកាចំនួន ៣៩.២៩៣ ដុល្លារអាមេរិក ជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៤២៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំរេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឡ ម៉យី** ដែលបានផ្តល់ថវិកាចំនួន ១០.០០០ USD ជួយសាងសង់សាលប្រជុំ របស់បញ្ជាការដ្ឋានយោធភូមិភាគ ទី ២ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកោះកុង

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៤ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងព្រះវិហារវត្តឧត្តមមុនីវង្ស ក្នុងស្រុកកំពង់សិលា ខេត្តកោះកុង ដូចមានខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ**

| | | |
|---|---|---|
| ១-លោក | **ភួក ម៉េង** | ថវិកា ១២.៩៣៣ USD |
| ២-លោក | **ម៉ឺង កេងឆេង** | ថវិកា ១១.០៣៣ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | |
|---|---|---|
| -លោកតា | **មួង ជាត់** | ថវិកា ៥.០០០ USD |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | |
|---|---|---|
| -លោកតា | **ហួត សេង** | ថវិកា ២.៣៥០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ៥ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៦១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកាជួយកសាង សមិទ្ធផលនានា ក្នុងវត្តក្រូចសើច ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ ៖

**ក ‐ មេដាយមាសស្ថាបនាជាតិ :**

- ព្រះតេជគុណ **ពេញ សាម៉ន** ថវិកា ១១.០៥០ USD

**ខ ‐ មេដាយប្រាក់ស្ថាបនាជាតិ :**

១ - លោក **សៀក វណ្ណា** ថវិកា ៦.១៣០ USD
២ - ឧបាសិកា **ម៉ាក់ វ៉ែន** ថវិកា ៥.៥២០ USD
៣ - លោក **ហង្ស ព្រែក** ថវិកា ៥.១៦០ USD
៤ - លោក **មុន្នី ហោវ៉ាត** ថវិកា ៥.០៨០ USD
៥ - លោក **រុន ឌុក** ថវិកា ៥.០៥០ USD
៦ - លោក **ឡៀង គួចហួត** ថវិកា ៥.០៥០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៦៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ហាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបសអភិបាលខេត្តកណ្តាល

### ស ំ រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយប្រាក់ស្ហាបនាជាតិ** ជូនលោក **ឃិត ប៊ុណ្ណា** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ៥.២២០ USD ជួយជួសជុលផ្លូវលំ ០១ ខ្សែ នៅឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៦៣ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងផ្លាស់ប្ដូរមុខងារនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ស ម្រេ ច**

**មាត្រា១** : ត្រូវបានតែងតាំងផ្លាស់ប្ដូរមុខងារនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនលោក វរសេនីយ៍ឯក **អៀង សីសត្ថា** អត្តលេខ ០០០៥៧២ នាយករង នាយកដ្ឋានបំពាក់ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស បច្ចុប្បន្នជា នាយការិយាល័យអនុព័ន្ធយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤៦៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ម៉ាន់ ធីរៈ** ដែលបានផ្តល់ថវិកាចំនួន ៨.៧៥០ USD និង ១២.៣៤៥.០០០ រៀល ជួយកសាងព្រះវិហារ និង ឧបដ្ឋានសាលា នៅវត្តគាថាវង្ស ឃុំត្រពាំងសាលាខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត កំពង់ស្ពឺ

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ០៦ រូប ដែលបានបរិច្ចាគថវិកា ជួយកសាងព្រះវិហារ និង សមិទ្ធផលផ្សេងៗ ទៀត ក្នុងវត្តទួលសុភី ស្រុកសំរោងទង និង វត្តអង្គជុំ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានខាងក្រោម ÷

**ក_មេដាយមាសស្ថាបនាជាតិ**

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះតេជគុណ | **ចែ** | **ឃឿន** | ចៅអធិការវត្តអង្គជុំ | បច្ច័យ | ២៥.៤៦០ USD |
| ២-លោក | **អ៊ុន** | **យុទ្ធ** | ប្រធានក្រុមហ៊ុនបូរីកម្មករ | ថវិកា | ១២.៥៥០ USD |
| ៣-លោកស្រី | **យូ** | **ខៃត** | នៅប្រទេសបារាំង | ថវិកា | ១០.៨៩៦ USD |

**ខ_មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | | | |
|---|---|---|---|---|---|
| ១-លោកស្រី | **គុច** | **សារឿន** | នៅសហរដ្ឋអាមេរិក | ថវិកា | ៣.២៦០ USD |
| ២-លោក | **ស្រ៊ុន** | **ម៉ូវ** | នៅភ្នំពេញ | ថវិកា | ២.៨៨៦ USD |
| ៣-លោក | **ឃុត** | **ខុន** | នៅសហរដ្ឋអាមេរិក | ថវិកា | ២.០៤០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧ.ភ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលសាធារណៈនានា ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ ÷

**ក ~ មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១ - លោក | **សាកាម៉ូតូ ស៊ុយណារូ** | ជនជាតិជប៉ុន | ថវិកា ៤៤.០០០ USD |
| ២ - លោកស្រី | **អ៊ីកាយូ** | ជនជាតិជប៉ុន | ថវិកា ២២.០០០ USD |
| ៣ - លោក | **ខ្វិក ពិជ័យ** | ជនជាតិខ្មែរនៅជប៉ុន | ថវិកា ១៧.០០០ USD |
| ៤ - លោក | **អ៊ឹង នៃឡេង** | ជនជាតិខ្មែរនៅភ្នំពេញ | ថវិកា ១១.៥០០ USD |

**ខ ~ មេដាយប្រាក់ស្ថាបនាជាតិ :**

- ឧបាសិកា **ឈុន តាំង** ថវិកា ៥.៦៩២ USD

**គ ~ មេជាងសារីវណ្ណស្ថាបនាជាតិ :**

១ - លោក **សេខ ម៉េងហ៊ុន** ថវិកា ៣.៨៩៤ USD

២ - លោក **សៅ សុខ** ថវិកា ២.៩៥០ USD

៣- លោក **លី ហួ** ថវិកា ១.៥០០ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:..២៦៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **មូល សាសនៈ** ប្រធានក្រុមហ៊ុន **Cam -Tai Cambodia Electric Power** ដែលបានចំណាយធនធានផ្ទាល់ខ្លួនអស់ទឹកប្រាក់ចំនួន ៣៧.៦៥៣ ដុល្លារអាមេរិក ក្នុងការកសាងកុដិ នៅវត្តលង្កា រាជធានីភ្នំពេញ និង មហាកុដិព្រះអង្គពាន់ នៅវត្តកំពង់ភ្នំក្នុង ភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ២៦៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសហគមន៍ ០១ និង សប្បុរសជន ០១ រូប ដែលបានចំណាយថវិកាជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ និង អណ្តូងទឹក ០១ នៅសាលាបឋមសិក្សាជ្រលងកក់ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់ចំនួន ២៥.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

១- សហគមន៍មិត្តភាពអាស៊ី ខ្មែរ- ជប៉ុន ( KAFS - JAFS )

២- លោក **តាកេស៊ី យូកាវ៉ា** ( Mr. TAKESHI YUKAWA )

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦៩...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **ឡូរីន ហ្គាលិនដូ** ( Lauryn Galindo ) ដែលបានលះបង់នូវធនធានផ្ទាល់ខ្លួន អស់ទឹកប្រាក់ចំនួន ១០៩.៥៥៣ USD សំរាប់បំរើដល់វិស័យសុខុមាលភាពសង្គម ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ឌិត្យ សំអូន** ព្រះចៅអធិការវត្តកំពង់ភ្នំក្នុង ដែលបានខិតខំនិមន្តបិណ្ឌបាត្របច្ច័យយកមកកសាងសមិទ្ធផល លើវិស័យអប់រំ និងព្រះពុទ្ធសាសនា នៅវត្តកំពង់ភ្នំក្នុង ស្រុកលើកដែក ខេត្តកណ្តាល សរុបបច្ច័យចំនួន ១.២៣២.៣១៥.២០០រ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៣០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៦ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា ក្នុងស្រុកបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ ÷

| | | | | |
|---|---|---|---|---|
| ១-ឧកញ៉ា | **ចិន យន** | ប្រធានរតនាគារជាតិ | ថវិកា | ៦១.១៨៨.៧០០ ៛ |
| ២-លោក | **មាស ប៊ុនថុន** | អនុប្រធានរតនាគារជាតិ | ថវិកា | ៤៣.៩៩៩.២០០ ៛ |
| ៣-លោក | **យុត ស៊ីនី** | ប្រធានរតនាគារខេត្តបន្ទាយមានជ័យ | ថវិកា | ៤២.២៦១.៨០០ ៛ |
| ៤-លោក | **ស៊ឹន សំរេច** | ប្រធានរតនាគារខេត្តបាត់ដំបង | ថវិកា | ៤១.៨៥១.៧០០ ៛ |
| ៥-លោក | **លឹម ចន្ទថៃ** | ប្រធានរតនាគារខេត្តពោធិសាត់ | ថវិកា | ៤១.៥០០.៦០០ ៛ |
| ៦-លោក | **ហ៊ួត វណ្ណាហាន** | អនុប្រធានការិយាល័យរតនាគារជាតិ | ថវិកា | ៤០.០៦៦.៥០០ ៛ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ... ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

A.Te.Bodha

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២៧ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

ការតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២៣០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា
- តាមសំណើរបស់ប្រធានរាជបណ្ឌិតសភាកម្ពុជា

## សំរេច

**មាត្រា១** : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប នៃរាជបណ្ឌិតសភាកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- លោក **អ៊ុំ ច័ន** ជាអនុប្រធានវិទ្យាស្ថានភាសាជាតិ មានឋានៈស្មើ **អគ្គនាយករង** ។

២- លោក **ប៉ែន ប៊ុនពិទ** ជាអនុប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម មានឋានៈស្មើ **អគ្គនាយករង** ។

៣- លោក **តាត់ ចាន់ថា** ជាលេខាអចិន្ត្រៃយ៍វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា២** : ផ្ទេរភារកិច្ចលោក **អ៊ាប មុន្នីរ** បច្ចុប្បន្នលេខាអចិន្ត្រៃយ៍ នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា អោយទៅបំរើការងារជា ប្រធានផ្នែករូបវិទ្យា និងថាមពល នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

A.Te.Bodha

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា១ មាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

A.Te.Bodha

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២៧៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

### សំរេច

**មាត្រា១** : ត្រូវបានតែងតាំងលោក **ម៉ែន យ៉ាន** ជាប្រធានក្រុមផែនការគណនេយ្យ នៃ អគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មការ-អចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**សំរេច**

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីគ្រប់គ្រង ០៣ រូប ជានាយកវិទ្យាស្ថាន នៃក្រសួងអប់រំ យុវជន និង កីឡា ។

១_ លោក ម៉ិន តារ៉ិន ជានាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស

២_ លោក ម៉ែម ចន្ថា ជានាយកវិទ្យាស្ថានពហុបច្ចេកទេស ព្រះកុសុមៈ

៣_ លោក អៀង សុដល ជានាយកវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៣៥ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី២៦ ខែតុលាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១ :** ត្រូវបានតែងតាំងលោកស្រី **គាន់ ស៊ីលន់** ជាប្រធាន នាយកដ្ឋានរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យបានសម្រេច ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល*** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...០៧...សរណន

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០២

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំបុណ្យជាតិ " ទិវាកុមារអន្តរជាតិ ១ មិថុនា ២០០២ "

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ។ នៅឆ្នាំ ២០០១ ប្រទេសកម្ពុជា បានរួមចំណែកក្នុងចលនាពិភពលោកដើម្បីកុមារ ដោយបានធ្វើយុទ្ធនាការទូទាំងប្រទេស " **ផ្តល់ការគាំទ្រចំពោះកុមារ** " ដែលទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ លទ្ធផលទាំងនេះ ត្រូវបានរាយការណ៍ក្នុងសម័យប្រជុំពិសេស ស្តីពីកុមារនៃអង្គការសហប្រជាជាតិ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ៨ ដល់ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០២ នៅទីក្រុង New York ។ ដើម្បីអបអរសាទរសម័យប្រជុំខាងលើ និង ក្នុងគោលបំណងពង្រឹងពង្រីកសកម្មភាពគាំទ្រដល់កុមារកម្ពុជា ដែលជាអ្នកបន្តវេនសំរាប់អនាគតនៃប្រទេសជាតិ អោយទទួលបាននូវសិទ្ធិកាន់តែល្អប្រសើរឡើងថែមទៀត ក្នុងឱកាសទិវាកុមារអន្តរជាតិ ១ មិថុនា ២០០២ ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដូចតទៅ :

១ - ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិ សម្បទា ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងពត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំ**ពិធីមហាស្រាព ទិន្នញ** និង កម្មវិធីកំសាន្តផ្សេងៗសំរាប់កុមារនៅវត្តភ្នំ នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០២ អោយបានឱឡារិក អធិកអធម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ។

២ - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាសំរាប់ពិធីនេះ អោយបានទាន់ពេលវេលា ដើម្បីធានាការចាត់តាំងសមស្រប តាមគោលបំណង និង សំណូមពរ ។

រាជរដ្ឋាភិបាល សូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និង ប្រជាពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រ ដល់កម្មវិធីនេះ អោយបានផុលផុស អធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំចាត់តាំងអនុវត្ត ប្រកបដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីសហការអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..០៩..ស.រ.ណ.ន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំត្រៀមរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម

## សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ

## ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា

ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃ អង្គារ ទី ១៨ ខែ មិថុនា ឆ្នាំ២០០២ ខាងមុខនេះ ។

-ដើម្បីសំដែងនូវភក្តីភាពប្រកបដោយកតញ្ញូតាធម៌ តបស្នងសងព្រះមហាករុណាទិគុណដ៏ធំធេងក្នុងមនោសញ្ចេតនាគោរពដឹងព្រះគុណដ៏ជ្រាលជ្រៅចំពោះសម្តេចម៉ែ ដែលព្រះអង្គបានលះបង់ព្រះកាយពលក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុជាតិមាតុភូមិអង្គរជាទីស្នេហា និងប្រជារាស្ត្រ ជាកូនចៅ ចៅទួតរបស់ព្រះអង្គ ពិសេសលើវិស័យមនុស្សធម៌ សង្គមកិច្ច សុខមាលភាពទូទៅ ។ល។

-ដើម្បីចូលរួមអបអរសាទរ ថ្វាយព្រះពរសព្ទសាធុការ បវរមហាប្រសើរ ចំពោះសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ក្នុងឱកាសព្រះរាជពិធីបុណ្យចំរើនព្រះជន្មរបស់ព្រះអង្គ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំ ដូចតទៅនេះ :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ សាលាខេត្ត-ក្រុង សាលារៀន រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ក្រុមហ៊ុនឯកជននានា ត្រូវរៀបចំតុបតែង បដា ពាក្យស្លោក តាំងព្រះឆាយាលក្ខណ៍ សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** មានតាំងភ្លើងពណ៌ និងមានពាក្យស្លោក ថ្វាយព្រះពរ ។

២-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវធ្វើលិខិតថ្វាយព្រះពរសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ឱ្យបានមុនថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ និងផ្ញើជូនបណ្តាញសារពត៌មាន វិទ្យុ និងទូរទស្សន៍ កាសែត ដើម្បីផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ ។

៣-ក្រសួងព្រះបរមរាជវាំង និងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ឱ្យបានសមស្របទៅនឹងប្រពៃណីសាសនា និងប្រពៃណីជាតិ តាមការសព្វព្រះរាជហឫទ័យរបស់សម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ។

៤-ក្រសួងពត៌មាន ត្រូវចាត់តាំងរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ-ឯកជន អំពីព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាព និងស្នាព្រះហស្តរបស់សម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ចំពោះប្រទេសជាតិ និងចំពោះ ប្រជារាស្ត្រ ឱ្យបានទូលំទូលាយ ។

៥-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់បណ្តាមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ចាត់តាំងសំដែងសិល្បៈ ជូនមហាជនកំសាន្តសប្បាយទៅតាមទីធ្លាសាធារណៈ នៅថ្ងៃ អង្គារ ទី ១៨ ខែមិថុនា ឆ្នាំ ២០០២ តាមខ្លឹមសារ និងពេលវេលាសមស្រប ។

៦-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាព ក្រោមឱវាទ ខេត្ត-ក្រុង បង្កើនកិច្ចការពារ រក្សាសណ្តាប់ធ្នាប់សង្គម សុវត្ថិភាព សន្តិសុខ បង្កលក្ខណៈ ជូនប្រជាពលរដ្ឋកំសាន្តសប្បាយ អបអរសាទរក្នុងព្រះរាជពិធីបុណ្យនេះ ឱ្យបានឧឡារិករះចិករធម៌ ស័ក្តិសមទៅនឹងព្រះកិត្តិនាម និងព្រះគុណូបការៈដ៏ធំធេងនៃសម្តេចម៉ែ ជាទីសក្ការៈ ។

ទទួលបានផែនការណែនាំនេះ ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងខេត្ត-ក្រុង ត្រូវចាត់តាំងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
និងគ្រប់ខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

---

- សូមថ្វាយព្រះពរសម្តេចម៉ែ ជាទីគោរពសក្ការៈ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ
- សូមថ្វាយព្រះពរបវរមហាប្រសើរ សម្តេចឪ សម្តេចម៉ែ មានព្រះសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ
- ជយោ ! ព្រះរាជាណាចក្រកម្ពុជា
- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍
- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ
- ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៩...សរណ

# សារលិខិត

## របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
## ថ្លែងក្នុងឱកាស អបអរសាទរទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក
## ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០២

- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមក្រាបថ្វាយបង្គំព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ និង សម្តេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ
- សម្តេចប្រធានព្រឹទ្ធសភា សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងរដ្ឋាភិបាល និងអង្គការអន្តរជាតិនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- បងប្អូនជនរួមជាតិទាំងអស់ជាទីគោរព

ថ្ងៃនេះក្នុងនាមប្រមុខរាជរដ្ឋាភិបាល ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងក្តីសោមនស្សរីករាយឥតឧបមាក្នុងការធ្វើសេចក្តីថ្លែងសារលិខិតទៅកាន់ជនរួមជាតិជាទីស្នេហា ដើម្បីសំដែងនូវឆន្ទៈ និងការប្តេជ្ញាចិត្ត ចូលរួមជាមួយរដ្ឋាភិបាល និងប្រជាពលរដ្ឋជាង ១០០ ប្រទេសលើសកលលោក ក្នុងបុព្វហេតុការពារថែរក្សា និងគាំពារបរិស្ថាន នៅព្រះរាជាណាចក្រកម្ពុជា បរិស្ថានតំបន់ និងបរិស្ថានភពផែនដីទាំងមូល ។

ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០២នេះ គឺជាឆ្នាំទី ៩ ហើយ ដែលប្រជាពលរដ្ឋកម្ពុជារួមជាមួយប្រជាជាតិជាង១០០ប្រទេសលើភពផែនដីយើងនេះ នាំគ្នាប្រារព្ធទិវាបរិស្ថានពិភពលោក ០៥មិថុនា និងជាឆ្នាំទី៧ផងដែរ ដែលប្រជាជាតិកម្ពុជាយើងកំណត់យកថ្ងៃនេះ ជាថ្ងៃប្រារព្ធទិវាបរិស្ថានជាតិព្រមជាមួយនិងប្រធានបទ ដែលប្រកាសឡើងដោយអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិហៅកាត់ថា យូណែប (UNEP) មានខ្លឹមសារថា " សូមផ្តល់នូវឱកាសវាសនា ល្អជានិច្ចដល់ភពផែនដី " (Give Earth a Chance = Donnons une chance à la planète) ។

យោងតាមប្រវត្តិនៃកិច្ចដំណើរការប្រជុំនៅ រីយ៉ូដឺហ្សានេរ៉ូ (Rio de Janeiro) ប្រទេសប្រេស៊ីលក្នុងឆ្នាំ ១៩៩២ ដែលបង្កើតឱ្យមានរបៀបវារៈទី២១ (Agenda 21) និងការកំណត់យកថ្ងៃទី០៥ មិថុនា ជាថ្ងៃប្រារព្ធទិវាបរិស្ថានពិភពលោក គិតមកដល់ឆ្នាំនេះគឺមានអាយុកាល ១០ឆ្នាំហើយ ។ ប៉ុន្តែដោយស្ថានភាពសត្យានុម័ត និងអត្តនោម័ត ខ្លឹមសារនានាដែលមានចែងនៅក្នុងរបៀបវារៈទី២១ ក្នុងន័យអភិវឌ្ឍន៍ដោយចីរភាព ទប់ស្កាត់ការខូចខាតបរិស្ថានទាំងគុណភាព និងបរិមាណមិនទាន់ទទួលជោគជ័យជាទីពេញចិត្តនៅលើក្របខ័ណ្ឌសកលលោកទាំងមូលនៅឡើយ ។ ដូច្នេះហើយបានជាមានកិច្ចប្រជុំពិភាក្សាបន្តបន្ទាប់ទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលលោក ដើម្បីរកដំណោះស្រាយជួយសង្គ្រោះភពផែនដី ។

ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០១ កន្លងមកនេះ នៅក្នុងកិច្ចប្រជុំ ថ្នាក់តំបន់ អាស៊ីប៉ាស៊ីហ្វិក ដែលបានធ្វើឡើងនៅរាជធានីភ្នំពេញ ដោយមានការចូលរួមពីប្រទេសចំនួន ៦២ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពិភពលោក នៅខែកញ្ញា នៅប្រទេសអាហ្វ្រិកខាងត្បូង ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និងកម្មវិធី "របៀបវារៈទី២១ Agenda21" ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបានថ្លែងសុន្ទរកថាលើកឡើងនូវទិដ្ឋភាពជារួមមួយចំនួនជុំវិញសភាពការណ៍នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ចនៅកម្ពុជា និងលើសកលលោក ព្រមទាំងបានឆ្លុះបញ្ចាំងឱ្យឃើញនូវកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលមេនិងកិច្ចការពារបរិស្ថាននៅកម្ពុជា បរិស្ថានតំបន់ និងបរិស្ថានសកលលោក ។ នៅពេលនោះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំក៏បានលើកឡើងនូវអនុសាសន៍មួយចំនួន ដើម្បីជំរុញឱ្យមានការអនុវត្តប្រកបដោយចីរភាព ដោយសង្កត់ធ្ងន់ទៅលើការកាត់បន្ថយភាពក្រីក្រ ជាគោលដៅចំបងនៃការអភិវឌ្ឍប្រកបដោយចីរភាព ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបានបញ្ចូលប្រធានបទ " សង្គ្រាមប្រឆាំង និងភាពក្រីក្រ " ជាសារដ៏សំខាន់បំផុតក្នុងសេចក្តីថ្លែងការណ៍នៅរាជធានីភ្នំពេញ អំពីផែនការតំបន់ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព (Phnom Penh Regional Platform on Sustainable Development) ។

ការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវឈរនៅលើគោលគ្រឹះបី គឺទី១ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងបរិស្ថាន ទី២ គឺស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទី៣ គឺការលើកស្ទួយវិស័យសង្គមកិច្ច អប់រំ សុខាភិបាល សមភាព និងសមធម៌ ។ ឯមូលដ្ឋានគ្រឹះដើម្បីធានាបាននូវជោគជ័យដ៏ពិតប្រាកដនៃការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រគឺអភិបាលកិច្ចល្អ ។

**បងប្អូនជនរួមជាតិជាទីស្នេហា !**

កម្ពុជាត្រូវបានគេចាត់ទុកជាប្រជាជាតិក្រីក្រមួយ ក្នុងចំណោមប្រទេសមួយចំនួនទៀតលើសកលលោក ដោយបណ្តាលមកពីមូលហេតុនៃសង្គ្រាមផ្ទៃក្នុងអូសបន្លាយជិតពាទសវត្ស ។ ដូច្នេះក្នុងការអនុវត្តកម្មវិធីនានាស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាអន្តរជាតិទាំងឡាយ នៅជួបប្រទះឧបសគ្គពហុសណ្ឋាន ។

ភាពក្រីក្របច្ចុប្បន្ន ដែលនៅមានសេសសល់នៅឡើយក្នុងចំណោមប្រជាពលរដ្ឋរបស់យើងមួយចំនួនបានបង្ខំដល់ការធ្វើអាជីវកម្មធនធានធម្មជាតិតាមរបៀបមួយដែលគ្មាននិរន្តរភាព ដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ពួកគេ ។ រាជរដ្ឋាភិបាលបានយល់យ៉ាងច្បាស់ពីការជះឥទ្ធិពលអាក្រក់ នៃភាពក្រីក្រជាមួយនឹងការរិចរិលបរិស្ថាន ។ ការកែទំរង់ព្រៃឈើ ជលផល ការគ្រប់គ្រងដីធ្លី កិច្ចការពារបរិស្ថាន ការកសាងសហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិនានាមានជាអាទិ៍ ការបង្កើតសហគមន៍ព្រៃឈើ សហគមន៍ជលផល សហគមន៍តំបន់ការពារធម្មជាតិ ។ល។ និងការលើកស្ទួយជាអាទិភាពវិស័យអប់រំ សុខាភិបាល សង្គមកិច្ច ត្រូវបានរាជរដ្ឋាភិបាលជំរុញ និងលើកកំពស់ការអភិវឌ្ឍប្រកបដោយចីរភាព ។

ការយកចិត្តទុកដាក់បញ្ហាយេនឌ័រ (Gender ) បានលើកទឹកចិត្តឱ្យមានការចូលរួមរបស់ប្រជាជន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ហើយបានរួមចំណែកយ៉ាងសំខាន់ដល់កិច្ចការពារបរិស្ថាន ។ រាជរដ្ឋាភិបាលបានកំណត់សតវត្សទី២១ នេះថាជាសតវត្សបរិស្ថាន ដោយយោងទៅលើអន្តរទំនាក់ទំនងបំពេញគ្នាទៅវិញទៅមករវាងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងកិច្ចការពារបរិស្ថាន ។

ប្រធានបទលើកឡើងដោយអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិនាឱកាសនោះ ដែលមានខ្លឹមសារថា "សូមផ្តល់នូវជោគវាសនាល្អជានិច្ចដល់ភពផែនដី" បានបង្កប់នូវអត្ថន័យ និងសកម្មភាពយ៉ាងជ្រាលជ្រៅបំផុត ហើយហាក់ដូចជាបានដាស់ស្មារតីមនុស្សជាតិគ្រប់រូបឱ្យក្រោកឈរ និងភ្ញាក់រលឹកចូលរួមថែរក្សាភពផែនដីយើង ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ដោយសារសកម្មភាពមនុស្ស ហើយវាក៏បានដង្ហោយហៅដល់បុគ្គលម្នាក់ៗ ឱ្យចូលរួមជួយព្យាបាលឱ្យបានសះស្បើយមុខរបួសភពផែនដី មានជាអាទិ៍គឺ សំណឹកដី ការកើនឡើងវាលរហោស្ថាន ការបាត់បង់ព្រៃឈើ ការបាត់បង់សត្វព្រៃ និងរុក្ខជាតិរាប់ម៉ឺនប្រភេទ ភ្លៀងមានជាតិអាស៊ីត ការទាញយកផលពីបាតសមុទ្រហួសហេតុ ការវាតទីដើម្បីប្រកបដំណាំកសិកម្ម និងការចិញ្ចឹមសត្វ ការប្រែប្រួលយ៉ាងអាក្រក់នៃអាកាសធាតុ ការរលាយទឹកកកនៅតំបន់ប៉ូល កំណើនបរិមាណសំណល់មានជាតិពុល ការហូរចូលប្រជាជនជនបទមកកាន់ទីក្រុងយ៉ាងគំហុក ការបំពុលខ្យល់ បំពុលទឹក និងការរំខានដោយសំលេង ។ល។ និង ។ល ។

ដោយឡែក នៅកម្ពុជាយើង បញ្ហាចំពោះមុខគឺការបាត់បង់ព្រៃឈើ និងការវិនាសនៃជីវៈចំរុះជាបញ្ហាដែល រាជរដ្ឋាភិបាលចាត់ទុកជាបញ្ហាអាទិភាព ហើយរាជរដ្ឋាភិបាលបានចាត់ទុកនិរន្តរភាពព្រៃឈើកម្ពុជា ជាអាយុជីវិតនយោបាយរបស់ខ្លួន ។

**បងប្អូនជនរួមជាតិជាទីស្នេហា !**

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងនូវការកោតសរសើរដោយស្មោះស្ម័គ្រចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន ដែលបានខិតខំបំពេញភារកិច្ចសំរេចជោគជ័យក្នុងកិច្ចការពារថែរក្សា និងគាំពារបរិស្ថានគួរជាទីមោទនៈ ។ ទន្ទឹមនេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណ

ដល់កិច្ចសហការ និងសហប្រតិបត្តិការល្អពីសំណាក់គ្រប់ស្ថាប័ននៃរាជរដ្ឋាភិបាល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃគ្រប់អង្គ ប្រជាពលរដ្ឋ កងកំលាំងប្រដាប់អាវុធ និងសិស្សានុសិស្សគ្រប់ភូមិសិក្សា ដែលបានធ្វើសកម្មភាពចូលរួមក្នុងកិច្ចគាំពារបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ។

ក្នុងឱកាសនេះដែរ ក្នុងនាមរាជរដ្ឋាភិបាល ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះរដ្ឋាភិបាលនៃប្រទេសជាមិត្ត អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល និងសប្បុរសជនជាតិ និងអន្តរជាតិនានា ដែលបានចូលរួមជួយឧបត្ថម្ភថវិកា សំភារៈ ធនធានមនុស្ស និងបញ្ញាញាណ ដើម្បីជួយទ្រទ្រង់ដល់សកម្មភាពគាំពារបរិស្ថានព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាបរិស្ថានក្នុងតំបន់ និងបរិស្ថានសកលលោកទាំងមូលផងដែរ ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង-ស្ថាប័ន កងកំលាំងប្រដាប់អាវុធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃ និងប្រជាពលរដ្ឋទូទាំងប្រទេស សូមមេត្តាចូលរួមអនុវត្តនូវគោលនយោបាយគាំពារបរិស្ថានរបស់រាជរដ្ឋាភិបាលឱ្យបានជាប្រចាំ និងកាន់តែសកម្ម ខ្លាំងក្លាជាងមុនថែមទៀត ។ បុគ្គលម្នាក់ៗត្រូវមានទស្សនៈថា " ភពផែនដីជាប្រភពនៃជីវិត ហើយយើងត្រូវផ្តល់ឱកាស ឱ្យភពផែនដីមានការរីកលូតលាស់តាមបែបធម្មជាតិរបស់វាផង ហើយរាល់ការធ្វើអាជីវកម្មធនធានធម្មជាតិ ត្រូវធានានិរន្តរភាពបរិស្ថានជានិច្ច " ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមថា ស្មារតីនៃការប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០០២ ពេលនេះនឹងក្លាយជាឆន្ទៈប្តូរផ្តាច់ដ៏មោះមុតរបស់ប្រជាជនយើង និងមនុស្សជាតិ ដើម្បីបុព្វហេតុបរិស្ថានភពផែនដី ។

**-ជយោ ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០០២ !**

**-សូមផ្តល់នូវជោគវាសនាល្អជានិច្ចដល់ភពផែនដី !**

**សូមអរព្រះគុណ អរគុណ !**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
លេខ : ៣៧៧ សហវ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិង សំណង់

-អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុង[illegible] រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល ។

-អនុវត្តតាមអនុក្រិត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

-អនុវត្តតាមប្រកាសលេខ ០០៤ សហវ-មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋទេយ្យ ចំណូល

-តាមការចាំបាច់ក្នុងការអនុវត្តន៍ច្បាប់ភូមិបាល

## សំរេច

**ប្រការ ១:** អនុញ្ញាតឱ្យយកសោហ៊ុយសេវាសុរិយោដីលើការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញប័ណ្ណទុតិយតា ការចេញប័ណ្ណតតិយតា ការផ្ទេរសិទ្ធិលើអចលនវត្ថុ ការចេញលិខិតបញ្ជាក់សុរិយោដី (ហ៊ីប៉ូតែក បញ្ចាំ ដាក់ធានា) ការចេញសាលាកប័ត្រពត៌មាន ការចេញលិខិតបញ្ជាក់ សុរិយោដី និងការថតចំលងឯកសារ ព្រមទាំងការបំពេញបែបបទ ឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងារ សុរិយោដី ។

**ប្រការ ២:** សោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់ដូចតទៅ :

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | |
|---|---|---|---|---|
| | | ដីផលិតកម្ម ឬ ដីភោគ | ដីលំនៅដ្ឋាន និង ដីសំរាប់សំណង់ទូទៅ | |
| | | | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត |
| ១ | ការចេញប័ណ្ណ ឬ ប័ណ្ណទុតិយតា ឬប័ណ្ណតតិយតា " ក្នុង ១ក្បាលដី " | ៥.០០០៛០០ | ១០០.០០០៛០០ | ៣៥០.០០០៛០០ |
| ២ | ការផ្ទេរអចលនវត្ថុ(ផ្ទេរដោយបំបែក ឬ ផ្ទេរទាំងមូល)" ក្នុង ១ប័ណ្ណ " | ៥០.០០០៛០០ | ៨០.០០០៛០០ | ១០០.០០០៛០០ |
| ៣ | ការបង្រួមក្បាលដី " ក្នុង ១ក្បាលដី " | ១០០.០០០៛០០ | ១២០.០០០៛០០ | ១៥០.០០០៛០០ |
| ៤ | ការចេញលិខិតបញ្ជាក់(ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា) " ក្នុង ១ក្បាលដី " | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |
| ៥ | ការចេញសាលាកប័ត្រពត៌មាន " ក្នុង ១ក្បាលដី " | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |
| ៦ | ការចេញលិខិតបញ្ជាក់សុរិយោដី " ក្នុង ១ក្បាលដី " | ១៥.០០០៛០០ | ១៨.០០០៛០០ | ២០.០០០៛០០ |

ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ សោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់អ្នកទទួលសិទ្ធិ ។ អ្នកទទួលសិទ្ធិអចលនវត្ថុក៏ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន ។

**ប្រការ៣ :** សោហ៊ុយសេវាសុរិយោដីលើការវាស់វែងដីដោយប្រើឧបករណ៍វាស់ស្ទង់ទំនើបត្រូវបាន កំណត់ដូចខាងក្រោម :

| ល.រ | បរិយាយ | សោហ៊ុយក្នុង១ហិកតា |
|---|---|---|
| ១ | ទំហំដីតិចជាង ១០ ហិកតា | ៣០.០០០៛០០ |
| ២ | ទំហំដីចាប់ពី ១០ ហិកតា ដល់ ៥០ ហិកតា | ១៥.០០០៛០០ |
| ៣ | ទំហំដីចាប់ពី ៥១ ហិកតា ដល់ ៣០០ ហិកតា | ១០.០០០៛០០ |
| ៤ | ទំហំដីចាប់ពី ៣០១ ហិកតា ដល់ ១.០០០ ហិកតា | ៨.០០០៛០០ |
| ៥ | ទំហំដីចាប់ពី ១.០០០ ហិកតាឡើងទៅ | ៦.០០០៛០០ |

ចំពោះដីដែលមានទីតាំងឆ្ងាយលើសពី៥០គីឡូម៉ែត្រពីអង្គភាពសុរិយោដី ម្ចាស់ដីត្រូវទទួល បន្ទុកបន្ថែមលើ :

១-សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក របស់មន្ត្រីជំនាញ ។

២-ថ្លៃបង្គោល និងការដាំបង្គោលព្រំ ។

៣-ចំពោះតំបន់ព្រៃភ្នំ សោហ៊ុយសេវាសុរិយោដីត្រូវគិតបន្ថែម២០%លើសោហ៊ុយសេវា វាស់វែងសរុប ។

**ប្រការ៤ :** រាល់ទំរង់បែបបទឯកសារសុរិយោដីដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមនិតិវិធី សុរិយោដី ។

**ប្រការ៥ :** -ការបង់ប្រាក់និងការទទួលប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមរយៈ រជ្ជទេយ្យករចំណូល នៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង។

-ក្នុងករណីចាំបាច់អាចបង្កើតរជ្ជទេយ្យករចំណូលរង នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខ័ណ្ឌ ។

-ការបោះពុម្ពនិងការបើកផ្តល់បង្កាន់ដៃចំណូលពីសោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់ ថវិការដ្ឋដែលចាត់ចែងអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ។

<u>ប្រការ៦ :</u> ការគ្រប់គ្រងចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមនិតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។

<u>ប្រការ ៧ :</u> ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់បែងចែកដូចខាងក្រោម :

១. ៧៥% សំរាប់បង់ចូលថវិការដ្ឋក្នុងនោះមាន៣៥% ដែលជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សំរាប់ចាត់ចែងចំណាយដល់អង្គភាពជំនាញសុរិយោដីក្រោមឱវាទ ។

២. ១៥% សំរាប់បំរើឱ្យគុណប្រយោជន៍ថវិការបស់ខេត្ត-ក្រុងក្នុងនោះមាន ៥% ដែលជាចំណែករបស់ស្រុក-ខណ្ឌ ។

៣. ១០% សំរាប់បំរើឱ្យគុណប្រយោជន៍ថវិការបស់ឃុំ-សង្កាត់ ។

<u>ប្រការ ៨ :</u> ចំណូលពីសោហ៊ុយសេវាសុរិយោដីត្រូវបង់ចូលថវិការដ្ឋនិងថវិកាខេត្ត-ក្រុងនៅរតនាគារខេត្ត- ក្រុងដោយកត់ត្រានៅក្នុងជំពូក២១ ប្រការ ០៣ កថាខ័ណ្ឌ១៩ ។ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដី ត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះ ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ប្រាក់ ។

<u>ប្រការ ៩ :</u> ផ្អែកលើការបូកសរុបសភាពការណ៍បង់ចំណូលប្រចាំត្រីមាសដូចមានចែងនៅក្នុងប្រការ៨ខាងលើ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ត្រូវលើកសំណើសុំចំណាយក្នុងវង្វង់ ៣៥%នៃចំណូលដែលបានបង់ចូលថវិការដ្ឋមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួលជូនវិញ តែត្រូវភ្ជាប់មកជាមួយ នូវ :

-សលាកប័ត្របង់ប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី

-របាយការណ៍ចំណាយនៃចំណែក៣៥%ដែលថវិការដ្ឋបានបើកផ្តល់លើកមុនដោយមានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់និងត្រឹមត្រូវ ។

និតិវិធីនៃការបើកផ្តល់ចំណាយ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក ១១-០១-១៤-០២ ។

<u>ប្រការ ១០ :</u> បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>ប្រការ ១១ :</u> អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន[illegible]ជាតិ អង្គភាពពាក់ព័ន្ធទាំងអស់ ដែល ...

ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់មានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាស នេះ ។

ប្រការ ១២ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសេវនកម្មជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

" ដើម្បីជូនជ្រាប "

- ដូចប្រការ១១ " ដើម្បីអនុវត្ត "
- ឯកសារ និង កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*******

ក្រសួងអប់រំ យុវជន និង កីឡា

លេខ....៣៩៤........អយក.ប្រក

# ប្រកាស

**ស្តីពីការទទួលស្គាល់សិស្សពូកែទូទាំងប្រទេសផ្នែក**

**អក្សរសិល្ប៍ គណិតវិទ្យា និង រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២ ឆ្នាំ ២០០២**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត ១៩៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស_រកម ០១ ៩៦_០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត ០៧ ៩៦ ៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ_បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ។
- យោងកំនត់ហេតុប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ គណិតវិទ្យា និង រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២ នាសម័យប្រលង : ២៣ ឧសភា ២០០២ ។

## សំរេច

ប្រការ១ :សិស្សពូកែ ថ្នាក់ទី ៩ និង ថ្នាក់ទី ១២ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និង រូបវិទ្យា នៃសាលារៀនចំនេះទូទៅដូចមានរាយនាមខាងក្រោម ត្រូវប្រកាសថា ជាជ័យលាភីទូទាំងប្រទេសក្នុងឆ្នាំ ២០០២ :

# ក-ថ្នាក់ទី៩

## ១-អក្សរសិល្ប៍ខ្មែរ

| ចំណាត់ថ្នាក់ | | នាម និង គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាលា | ខេត្ត-ក្រុង |
|---|---|---|---|---|---|---|
| លេខ | ១ | ឡៃ ចាន់ណារ៉ា | ប្រុស | 15/12/87 | វិ. សម្ដេច ជួន ណាត | កំពង់ចាម |
| លេខ | ២ | សួង ម៉ាក់ | ប្រុស | 10/04/86 | វិ. សម្ដេចម៉ែ | កំពង់ចាម |
| លេខ | ៣ | ហ៊ិន ស៊ីណាត | ស្រី | 04/01/87 | វិ. ព្រះសីហនុ | កំពង់ចាម |
| លេខ | ៤ | អ៊ឹង សុមាល័យ | ស្រី | 03/03/86 | វិ. បឹងកេងកង | ភ្នំពេញ |
| លេខ | ៤ | ផាន់ វិសាខា | ស្រី | 12/04/85 | អនុវិ. ទីរួមខេត្តកំ. ឆ្នាំង | កំពង់ឆ្នាំង |
| លេខ | ៤ | ងន រតនា | ស្រី | 01/10/87 | វិ. សន្ធរម៉ុក | ភ្នំពេញ |
| លេខ | ៧ | អៀន សុផានីកា | ស្រី | 17/06/87 | វិ. ជា ស៊ីម តាកែវ | តាកែវ |
| លេខ | ៧ | នៅ តុលា | ស្រី | 08/10/86 | វិ. តាំងក្រសាំង | កំពង់ធំ |
| លេខ | ៩ | ស៊ាង សំបូរ | ប្រុស | 22/02/87 | វិ. បាក់ទូក | ភ្នំពេញ |
| លេខ | ១០ | ផែម សំណាង | ប្រុស | 13/07/86 | វិ. សម្ដេចឪ | ប. មានជ័យ |

## ២-គណិតវិទ្យា

| ចំណាត់ថ្នាក់ | | នាម និង គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាលា | ខេត្ត-ក្រុង |
|---|---|---|---|---|---|---|
| លេខ | ១ | ឃុយ សៀនសុភ័ក្រ | ស្រី | 28/04/87 | វិ. ព្រះរាជសម្ភារ | កំពត |
| លេខ | ២ | ម៉ង់ ចិត្រា | ប្រុស | 05/07/87 | វិ. វត្តកោះ | ភ្នំពេញ |
| លេខ | ៣ | កៅ វិបុល | ប្រុស | 12/02/87 | អនុវិ. ក្រចេះក្រុង | ក្រចេះ |
| លេខ | ៤ | អេង ឡាយ ហ | ប្រុស | 23/05/87 | វិ. សម្ដេចឪ | ប. មានជ័យ |
| លេខ | ៥ | ហាក់ ព្រីសុលក្ខិណា | ស្រី | 11/11/86 | អនុវិ. វត្តភ្នំ | ភ្នំពេញ |
| លេខ | ៦ | ហេង សុផារ៉ា | ស្រី | 25/05/86 | អនុវិ. សេរីភាព | កណ្ដាល |
| លេខ | ៧ | ទឹម យសបញ្ញា | ប្រុស | 25/05/87 | វិ. ព្រះរាជសម្ភារ | កំពត |
| លេខ | ៨ | ហេង សុភី | ស្រី | 14/05/87 | វិ. ពោធិសាត់ | ពោធិសាត់ |
| លេខ | ៩ | លីម ហុងកៃ | ប្រុស | 08/08/86 | វិ. ព្រះរាជសម្ភារ | កំពត |
| លេខ | ១០ | គីម ណារិន | ប្រុស | 09/08/87 | អនុវិ. សេរីភាព | កណ្ដាល |

### ៣-រូបវិទ្យា

| ចំណាត់ថ្នាក់ | | នាម និង គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាលា | ខេត្ត-ក្រុង |
|---|---|---|---|---|---|---|
| លេខ | ១ | ច្រឹង សម្ផស្ស | ប្រុស | 25/11/87 | អនុវិ. ចតុមុខ | ភ្នំពេញ |
| លេខ | ២ | ម៉េង សេងគ្រី | ប្រុស | 02/01/86 | វិ. ព្រះបាទសុរាម្រឹត | កំពង់ឆ្នាំង |
| លេខ | ៣ | រឿន សុវណ្ណរិទ្ធ | ប្រុស | 15/08/87 | អនុវិ. ផ្សារដើមថ្កូវ | ភ្នំពេញ |
| លេខ | ៤ | អាំង លាងមុយ | ស្រី | 05/04/87 | វិ. ស្ទឹងសោភ័ណ | កំពង់ធំ |
| លេខ | ៥ | គាន វ៉ាន់នី | ស្រី | 01/12/85 | វិ. សម្តេចឪ | ប. មានជ័យ |
| លេខ | ៦ | មាស សុខា | ប្រុស | 15/03/87 | វិ. ពោធិសាត់ | ពោធិសាត់ |
| លេខ | ៧ | អ៊ុំ សំណាង | ស្រី | 13/05/88 | វិ. បាក់ទូក | ភ្នំពេញ |
| លេខ | ៨ | ហួ វិសិដ្ឋ | ប្រុស | 07/11/88 | វិ. ស្ទឹងសោភ័ណ | កំពង់ធំ |
| លេខ | ៩ | ទូច លីដា | ស្រី | 01/06/87 | វិ. ពោធិសាត់ | ពោធិសាត់ |
| លេខ | ៩ | ចាន់ គីមហៀង | ប្រុស | 28/07/87 | វិ. ហ្សាម៉ាន់ | ភ្នំពេញ |

## ខ-ថ្នាក់ទី ១២

### ១-អក្សរសិល្ប៍ខ្មែរ

| ចំណាត់ថ្នាក់ | | នាម និង គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាលា | ខេត្ត-ក្រុង |
|---|---|---|---|---|---|---|
| លេខ | ១ | សុក ខែមបណ្ឌិត | ប្រុស | 25/11/85 | វិ. ព្រះស៊ីសុវត្ថិ | ភ្នំពេញ |
| លេខ | ២ | មួយលី វិច្ឆិកា | ស្រី | 20/03/85 | វិ. បាក់ទូក | ភ្នំពេញ |
| លេខ | ៣ | ហ៊ុន ឧត្តមស្ទិយា | ស្រី | 17/10/84 | វិ. ព្រះស៊ីសុវត្ថិ | ភ្នំពេញ |
| លេខ | ៤ | លី ឌីនូរី | ប្រុស | 05/09/85 | វិ. ព្រះមុនីវង្ស | បាត់ដំបង |
| លេខ | ៥ | យឹម ចន្ទា | ស្រី | 30/07/84 | វិ. បាក់ទូក | ភ្នំពេញ |
| លេខ | ៦ | សួង សុវណ្ណ | ប្រុស | 05/10/85 | វិ. ព្រះស៊ីសុវត្ថិ | ភ្នំពេញ |
| លេខ | ៧ | ឌី ចាន់ធី | ស្រី | 15/08/85 | វិ. ទួលទំពូង | ភ្នំពេញ |
| លេខ | ៨ | គីក រតនា | ស្រី | 30/04/85 | វិ. ទួលទំពូង | ភ្នំពេញ |
| លេខ | ៩ | ចៅ សែនអរុណរ័ត្ន | ស្រី | 29/03/83 | វិ. សន្ធរម៉ុក | ភ្នំពេញ |
| លេខ | ១០ | អ៊ាម សំអាត | ប្រុស | 17/01/86 | វិ. កំពង់ត្របែក | ព្រៃវែង |

## ២-គណិតវិទ្យា

| ចំណាត់ថ្នាក់ | | នាម និង គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាលា | ខេត្ត-ក្រុង |
|---|---|---|---|---|---|---|
| លេខ | ១ | លីម រតនៈ | ប្រុស | 20/05/84 | វិ. ព្រះមហាក្សត្រីយានីកុសុមៈ | ក្រចេះ |
| លេខ | ២ | សួ យ៉ាដា | ប្រុស | 11/07/85 | វិ. ទួលទំពូង | ភ្នំពេញ |
| លេខ | ៣ | ហៃ រតនា | ប្រុស | 10/01/84 | វិ. ទួលទំពូង | ភ្នំពេញ |
| លេខ | ៤ | សន សុធា | ប្រុស | 02/06/83 | វិ. សម្តេចឳ | ប. មានជ័យ |
| លេខ | ៥ | ធាម សុខវិបុល | ប្រុស | 30/05/85 | វិ. ព្រះស៊ីសុវត្ថិ | ភ្នំពេញ |
| លេខ | ៦ | អ៊ឹម វិប៊ុលកា | ប្រុស | 27/01/85 | វិ. បឹងត្របែក | ភ្នំពេញ |
| លេខ | ៧ | ឈី វិជ្ជ៉ា | ស្រី | 02/07/85 | វិ. ហ៊ុន សែន កោះធំ | កណ្តាល |
| លេខ | ៨ | អ៊ិត សារាដេ | ប្រុស | 23/03/85 | វិ. បាក់ទូក | ភ្នំពេញ |

## ៣-រូបវិទ្យា

| ចំណាត់ថ្នាក់ | | នាម និង គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាលា | ខេត្ត-ក្រុង |
|---|---|---|---|---|---|---|
| លេខ | ១ | ផេង បូរ៉ា | ប្រុស | 01/01/84 | វិ. ព្រះរាជសម្ភារ | កំពត |
| លេខ | ២ | ម៉េង ឫទ្ធី | ប្រុស | 10/10/86 | វិ. បាក់ទូក | ភ្នំពេញ |
| លេខ | ៣ | ឆេង រិទ្ធី | ប្រុស | 07/10/84 | វិ. ជា ស៊ីម តាកែវ | តាកែវ |
| លេខ | ៤ | វៀង ជីវុធ | ប្រុស | 28/02/85 | វិ. ព្រះស៊ីសុវត្ថិ | ភ្នំពេញ |
| លេខ | ៥ | ឡុង វឌ្ឍនៈ | ប្រុស | 16/11/85 | វិ. ទួលទំពូង | ភ្នំពេញ |
| លេខ | ៦ | សាន់ តេងសុជាតា | ប្រុស | 09/09/86 | វិ. ព្រះស៊ីសុវត្ថិ | ភ្នំពេញ |
| លេខ | ៧ | សុខ ធីតា | ស្រី | 16/06/86 | វិ. ព្រះមុនីវង្ស | បាត់ដំបង |
| លេខ | ៨ | ហ៊ា ធារិត | ប្រុស | 01/09/84 | វិ. ក្រូចឆ្មារ | កំពង់ចាម |
| លេខ | ៩ | អ៊ឹម គឹមស៊ី | ប្រុស | 07/10/85 | វិ. បរនេហស បាទី | តាកែវ |
| លេខ | ១០ | លាក់ សុភារៈ | ប្រុស | 30/12/84 | វិ. ហ៊ុន សែន ស្អាង | កណ្តាល |

ប្រការ២ :សិស្សពូកែថ្នាក់ទី ៩ និងថ្នាក់ទី ១២ ដែលជាជ័យលាភីទូទាំងប្រទេស ត្រូវបានទទួលរង្វាន់ពីរដ្ឋ ទៅតាមចំនាត់ថ្នាក់ និងសំភារៈផ្សេង ៗ ដូចខាងក្រោម .

១_ប្រកាសទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និង កីឡាមួយច្បាប់ ។

២_មេដាយមួយគ្រឿង ( ពីលេខ ១ ដល់លេខ ៣ ) ។

៣_វិញ្ញាបនប័ត្រសិស្សពូកែទូទាំងប្រទេសមួយសន្លឹក ។

៤_ប្រាក់រង្វាន់

| | | | |
|---|---|---|---|
| លេខ ១ | ៨០០.០០០ រៀល | លេខ ៦ | ៦៥០.០០០ រៀល |
| លេខ ២ | ៧៧០.០០០ រៀល | លេខ ៧ | ៦២០.០០០ រៀល |
| លេខ ៣ | ៧៤០.០០០ រៀល | លេខ ៨ | ៥៩០.០០០ រៀល |
| លេខ ៤ | ៧១០.០០០ រៀល | លេខ ៩ | ៥៦០.០០០ រៀល |
| លេខ ៥ | ៦៨០.០០០ រៀល | លេខ ១០ | ៥៣០.០០០ រៀល |

